Rœung "Neang Chompathong"

(ប-២៩-៧-៣៧៦)

# រឿងនាងជំពូថោងខ្មែរ



ទ-ទ
109

# សៀវភៅដែលផ្សាយចេញពីគេហស្ថាន គិម-គី

| | | |
|---|---|---|
| ច្បាប់បង្រៀនក្មេង . . . . . . . . . | ១ សៀវភៅថ្លៃ | ១០៛០០ |
| ព្រះគោព្រះកែវ ទី ១ ដល់ទី ៧ ចប់ . . . | ,, | ៨៛០០ |
| តេះផាដឹឌិន ទី ១ ដល់ទី ៧ ចប់ . . . . . | ,, | ៨៛០០ |
| ទឹកពិស្ពាក់ ទី ១ ទី ២ ចប់ . . . . . . | ,, | ៨៛០០ |
| កាព្យកសាន្តបិត្ត . . . . . . . . . | ,, | ៦៛០០ |
| រឿងធនូបៀង ទី ១ ទី ២ ចប់ . . . . | ,, | ៨៛០០ |
| រឿងជេញជ័យ . . . . . . . . . . | ,, | ១២៛០០ |
| រឿងអាឡាដាំងមនុស្សម្នាក់ទិញចង្កៀងទិព្វ | ,, | ១៤៛០០ |
| រឿងព្រះសុធន នាងកែវមនោរា ទី ១ ទី ៤ ចប់ | ,, | ៩៛០០ |
| រឿងវិបុលសគ្រាមទី ១ . . . . . . . | ,, | ១០៛០០ |
| ,, ,, ទី ២ . . . . . . . | ,, | ១៤៛០០ |
| ,, ,, ទី ៣ . . . . . . . | ,, | ១២៛០០ |
| នាងពីរដណ្ដប់ ពុទ្ធសែននាងកង្រី . . . | ,, | ១០៛០០ |
| ព្រះបទុមគោរប់ ទី ១ ទី ២ . . . . . . | ,, | ១០៛០០ |
| ,, ,, ទី ៣ ចប់ . . . . . . | ,, | ១២៛០០ |
| បងប្អូនពីរនាក់ . . . . . . . . . | ,, | ១០៛០០ |
| ក្បួនភាយទឹងសំឡោកផ្សេងៗ . . . . | ,, | ១៥៛០០ |
| ច្បាប់បង្ហាត់ទាហាន . . . . . . . | ,, | ៥៛០០ |
| រឿងជ័យសុរង្ស ទី ១ ដល់ទី ៤ ចប់ . . | ,, | ១០៛០០ |
| រឿងព្រះមហោសថ ទី ១ . . . . . . | ,, | ១០៛០០ |
| ,, ,, ទី ២ ទី ៣ . . . . | ,, | ៨៛០០ |

1953 - 5
ARCHIVES NATIONALES
B. M - 235
80



ដោយខ្ទាបព្រះរាជសារផ្ញា ពុំគួរសោះសា
ហាក់ខ្ញុំប្រមាថសោតហោង ៗ ហើយអស់ពេជឃាដទ្រើសឃ្មួន
នាំនាងចរផ្គង ចុះបាកប្រាសាទសោភា ៗ
នាងយំផាលដំឪក កែកិតមហិមា
សស្រោបសស្រាកនេត្រនាង ៗ ស្រីវត្នសោកក្ដាក់យាសយាង
ទប់ព្រះកាយនាង ជេងជោងងោងអង្គពេកក្រៃ ៗ
ហើយថាឱព្រះវៀមថ្ងៃ ម្ដេចម្ដងនេះនៃ
ក្ទាំងក្មួចពាក្យសច្ចសត្តិយា ៗ ក្មួចទាំងពាក្យពីយក្សា
ក្មួចក្ដីស្នេហា សំឡុតសំឡាញមុនមក ៗ
ឱព្រះវៀមរាជពន្ទុក ម្ដេចឡើយស្ដេចយក
ពាក្យពីប្រាំពីរពុទ្ធិតា ៗ ម្ទេះសំផាលក្រៃក្រោធា
ពុំពីចារណា ទូវដោយសុភាពពិតត្រង់ ៗ
ប្រែប្រាស់លៃងលះបាត់បង់ ស្នូទ្យសម្ទាប់អង្គ
អញខ្ញុំពិតពុំករុណា ៗ ពុំដឹងកិច្ចកល់កាបផា
រីបុត្រពំនារ មិនដឹងផារសប្បុរៃខ្យ ៗ
ស្ដេចពុំផ្ទាបព្រះហឫទ័យ ពីបុត្រថ្មើមថ្ងៃ
បណ្ដូលបណ្ដោចសង្សា ៗ ឱស្ងួនខ្ញុំមខ្លួនត្រកាល
ម្ដាយឥតស្រយ៉ោល លើយល្ហៃទំនេទុក្ខា ៗ
ទុក្ខមួយព្យុះគៅនៃបា ទូវព្រះព្យុកា

ស្តែងស្តេចគន់ពាពណាសី ៗ ទូកមួយឯអាសុរី
គុណាធូនឥតបី សោតសឹងជាព្រះជីតា ៗ
ទូកមួយព្រះបិតាបា ម្តាយនឹងឃ្លាតឃ្លា
លំនៅទីទួលជួបជាក់ ៗ ទូកមួយមាសម័តរលក្ស
ក្តីនើយឥតអ្នក នូវដឹងដំណឹងសួនក្យា ៗ
ទូកមួយគិតឯអាត្មា ម្តាយមិញមានា
ប្រាកដនាថ្ងៃនេះហោង ៗ ប្រែប្រាសទិពសនេះម្តង
សំពុំបានសង ព្រះគុណព្រះករុណាថ្ងៃ ៗ
កាលនោះពេជឃាតទីភ័យ នាំនាងនាថថ្ងៃ
ទៅដល់មណ្ឌលពេនរត៍ រិទ្យាគក្កមាគិតក្តាត់
ឈោឈោតស្នុះស្នាត់ រត់មករហាមនេត្រនៃ ៗ
បំណងប៉ងបីនូវខ្សែ ដិបដនដប្រែតៃ
មូលមួយសម្តេចពន្ទិតា ៗ កាលនោះទាំង៤ក្សត្រា
គិលៀនថ្ងៃថ្វា យុធយល់សម្តេចម្ហេសី ៗ
ចរចូលក្រាបទូលក្សត្រី ប្រការរតល់អ្វី
ព្រះរៀមស្តេចធ្វើទោសា ៗ ទោះទោសធ្ងន់ស្រាលក្តីណា
អាលអ្វីក្រោធា ពុំរិះពុំរើនរកច្បាប់ ៗ
ជឿតែពាក្យនាងឯកសត្វ ហើយមកសម្លាប់
ស្រែកស្រែបសើរសោកា ៗ កុំព្រួយព្រះរាជចិន្តា

ខ្ញុំសូមទោសា
ក្រែងបានជួបគិតនេះម្តង ៗ
នាងស្តាប់កិលៀងសាសង
នាងអរក្តាត់ហោង
តាមតែនៅមានមេត្តា ៗ
បើកូនខ្ញុំសូនមរនា
នេះឥឡូវពផា
អាសាសូន្យសោះគុណទៅ ៗ
បើបុត្រពិសុទ្ធិរស់នៅ
គុណអ្នកនេះហៅ
ប្រោសប្រស់ឲ្យរស់ជន្មា ៗ
ខ្ញុំម្តេចនឹងក្តួចឡើយណា
ទូលទុកសិរលា
ដ៏ពបលុះដល់ជីវី ៗ
ក្សិណ្ណោះទាំង ៤ ភូមី
ផ្តាំអស់មន្ត្រី
នូវអស់ទាហានអាសា ៗ
កុំអាលឲ្យនាំធីតា
រុងអញយាត្រា
ទៅទូលក្រែងស្តេចប្រុសប្រាណ ៗ
ស្រេចទើបចតុក្សត្រក្សាន
ស្តេចលីលាថ្កាន
ចរបូលទៅទូលពុំលុង ៗ
បពិតសូម្មានព្រះអង្គ
ពុំបេរនូវទ្រង់
ករុណាសម្តេចមហេសី ៗ
ទោះទោសធ្ងន់ស្រាលម្តេចក្តី
សូមស្តេចប្រណី
អាចឲ្យសង្កត់ទេយ្យា ៗ
អាសូរព្រះប្អូនតំអារ
ប្រសើរសោភា
ឥតស្រីណាផ្ទឹមស្មើបាន ៗ
នាងទ្រង់នលាក់កល្យាណ
រកទៀតក៏គ្មាន
ប្រហាក់ប្រហែលស្រីថ្ងៃ ៗ
នាងនាថពបសាល្មមល្មៃ
លើសលើកញ្ញត្រែ

ប្រកបតាំងនៅរូបប៉ា ៗ ទោសទេពតាំងធកាមា
ឥន្ទ្រព្រហ្មនានា សោតសឹងសរសើរបារមី ៗ
ទឹងរកយល់ក្រកំបី យកទោសក្សត្រី
ដោយពាក្យប្រាំពីរធីតា ៗ សោតខុសដោយពាក្យបេដ្ឋា
ទឹងក្រុងអាសុរ ក្រែងកើតកោលាហលហាន ៗ
ទឹងកើតអន្តរកាប់អន្តរធាន ព្រស្ដុផងសត្វស្ថាន
កក្រើកអំពើកពេកពន់ ៗ ដោយតេជរិទ្ធិសឹងហុន
មនុស្សម្នាមហាជន នោះទឹងវិនាសក្សិណក្បៃ ៗ
ទោសតាំងព្រះបាទជៀសដៃ ពុំលែងឡើយនៃ
អំពល់អម្ពើគួរស្ញែង ៗ ទោះបីយើងទឹងខំខែង
តាំងតជាញដែង ពាធានូវពលយុងយួន ៗ
នេះឥឡូវក្សត្រយក្ខស្ដេចទ្រង់ គុណធ្ងន់ម្ដេចបង់
ព្រះគុណព្រះករុណាថ្លៃ ៗ យល់យើងឥតអធ្យាស្រ័យ
បំភ្លេចគុណនៃ ពុំដោយគន្លងធមិថា ៗ
កាលនោះដៃដេតកជា ស្ដាប់ ៤ ក្សត្រា
គំនិតគំនាប់អភិប្រាយ ៗ ហេតុតែសីលសិទ្ធិសាយ
ឲ្យក្សត្រពទ្រាយ វង្វេងពុំធ្វេងឡើយណា ៗ
ពុំដឹងខុសគាប់កាចជា មមីមហិមា
ព្រះសូរបន្ទូលឆ្លើយស្នង ៗ ជានៃហៃមហាជាបង

កុំបីសាសង | ទទួលទទៃនាយអាយ ។
ទោះបីក្សត្រយក្ខរិទ្ធិសាយ | ចិនទំបីទំលាយ
ទំលុះលើសលែងបុទ្ធី ។ | ហោមចាប់មនុស្សក្នុងធានី
តាមបុណ្យបារមី | ពិជ័យសង្គ្រាមបីនូវគ្នា ។
ពំផ្សងស្តេចយកកស្ត្រា | ប្រលក់គង្គា
ទទឹកទទេឥតសព្វ ។ | បើបងពុំឲ្យសម្លាប់
បូលបងទៅប្រាប់ | ឲ្យបរបន្តេញចេញឆ្ងាយ ។
កុំនៅទីទៀបនាយអាយ | កើតក្តៅក្រហាយ
អំពើអំពល់ពំក្សាន ។ | ក្សិណ្ណោះក្សត្រ ៤ ប្រធាន
សៀមស្មាត់ពុំហ៊ាន | ដំទាស់ទទឹងអាជ្ញា

## បទកាក

ក្សិណ្ណោះក្សត្រា | ទាំង ៤ គ្រាបលា | បរបេញបុះថ្កាន
ដើរដល់ពេជឃាត | ព្រះបាទក្សត្រក្សាន | ព្រះទិស្សសងសាន
ប្រាយប្រាប់ទៅថា ។ | ហៃអស់ពេជឃាដ | ឥឡូវព្រះបាទ
ឥស្សរសិរសា | ស្តេចទ្រង់ព្រះក្សាន | មែនមានមេត្តា
ពុំឲ្យអស់គ្នា | សម្លាប់ឡើយហោង ។ | ស្តេចឲ្យបន្តេញ
ឲ្យទាំងបរបេញ | កំនៅនេះម្តង | តាមតែធីតា
យាត្រាត្រែបផ្គង | កុំឲ្យគ្នាផង | ប្រមាទនាងណា ។

ក្សត្រ ៤ ព្រះអង្គ ទឹកភ្នែកលលុង អាសូរដេយព្យា
បន្ទូលប្រាយប្រាប់ រៀបរាប់ថ្លែងថា អញ្ជើញយាត្រា
ចេញទៅនេះម្តង ៗ ខ្ញុំនឹងទូលលាស់ ចិតខំឲ្យណាស់
ហើយហាក់ខ្ញុំផ្គង យល់អស់ចំណេះ ខ្ញុំម្ទះហើយហោង
ស្រីរត់ប្យាស់ប្យង កុំអន់ចិន្តា ៗ ខ្ញុំវែងប្រណី
ឯកអង្គក្សត្រី ត្រេបដោយអត្ថា ប្រុងប្រាណប្រយ័ត្ន
សិងសតូនា ៗ ដោយដងមាគា កុំប្រហែសប្រាណ ៗ
នាងស្តាប់សំដី ចតុប្រកី ហើយនាងកល្យាណ
អាឯងកន្ទង នេះម្តងដ្បិតបាន រស់រួចផន្ទបាន
មែនមិនមរនា ៗ នាងនាថស្រីថ្លៃ បន្ទូលថាហៃ
ក្សត្រ ៤ អង្គា គុណនេះវែងធ្ងន់ ពេកពន់មហិមា
ស្មើព្រះបិតា បង្កើតនេះម្តង ៗ ពេជឃាដសោតស្តាប់
ស្រាយនាងប្រញាប់ ពុំលុង ឡើយហោង នាំនាងស្រីថ្លៃ
ដល់ព្រៃតម្តង អស់ពេជឃាតផង ក្រញូក្រាបលុតលា ៗ
អាណិតនាងក្រៃ បរបាកឃ្លាតឃ្លៃ ទៅតែឯកា
សឹងយុំសឹងសោក អាមោកគ្រប់គ្នា សុំស្មាទោសលា
នឹងនាងប្យាស់ប្យង ៗ កាលនោះធីតា ប្រសើរសោភា
រស់ដូចបំណង នាងពុំប្រែប្រាស់ លាក់លះព្រះបង
ហើយលីលាផ្គង ព្រះរៀមកជា ៗ ឡើងលើប្រាសាទ

ប្រសើរស្អាងស្អាត ខ្ញុំទូលថ្លែងថា បពិត្រព្រះអង្គ
សូមទ្រង់ករុណា ស្ងួនគ្រងរាជ្យ មេត្តាប្រណី ៗ
ទោសខ្ញុំធំធ្ងន់ ធ្ងន់ស្រាលក្តីហោង សូមព្រះចក្រី
លើកលែងទោសា មធុតាមេត្រី រួមរាក់បេត្តី
ជាខ្ញុំបាទា ៗ ខ្ញុំធ្លាប់ជាខ្ញុំ ព្រះអង្គឧត្តម
ជាម្ចាស់សិរសា ឥឡូវទឹងបាក លាកលះលីលា
ព្រះអើយប្អូនផ្សា ទ្រង់តឹងស៊ើរប្រែះ ៗ ប្អូនមិនដឹងខ្លួន
ថានឹងមកជួន ទុក្ខទោសដល់ម្ទេះ បាបអ្វីខ្វែង
ឲ្យទ្រង់ប្អូនប្រែះ ខានបាននៅនេះ នៃបទឹងដេផ្ទា ៗ
ប្អូនធ្លាប់ប្រតិបត្តិ អង្គព្រះរៀមរត ឥស្សរសិរសា
ខ្ញុំបង់នៅជឿ ខ្លួនបើក្យត្រា ស្មើព្រះបិតា
បង្កើតខ្លួនខ្ញុំ ៗ កាលនោះដេយ្យា ប្រាំពីរអង្គា
ពុទ្ធនាងនាថយុំ រង់ចាំងបង់ចិត្ត ខាំមាត់មុខមាំ
ពុំនៅសំងំ បរបេញយាត្រា ៗ ដើរដល់ទាញបិទ
ទ្វារមិញជាប់ជិត ហើយនាងថ្លែងថា ហៃអស់មន្ត្រី
សេណាសេនា ម្តេចពំនាំពា នៅថ្វីព្រងើយ ៗ
ព្រះអង្គស្តេចធ្មុំ ឲ្យអ្នកទោសយុំ សូរសព្ទល្វើយ ៗ
ពុំដឹងខុសគាប់ សៀមស្ងាត់កន្តើយ ពុំខ្លាចខ្លួនឡើយ
ទោសដល់អាត្មា ៗ កាលនោះមន្ត្រី ពុទ្ធនាងទេវី

ប្រាំពីរអគ្គា      គិតឯងខ្វបខ្វាប      អំណាចចេស្តា
ទើបទូលធីតា      នូវពាក្យមេត្រី ៗ      ស្រីរតឧត្តម
កុំស្តេចទួញយំ      លើមន្ទុល់ទី      ចូលអញ្ជើញចេញ
វិលវិញទៅខ្ចី      កុំម្ចាស់សិរសី      នូវនេះឡើយណា ៗ
សម្តេចក្សត្រី      នាងត្រុសំដី      ប្រាំពីរធីតា
នូវអស់មន្ត្រី      សេនីយោធា      បន្តេញច្នោះណា
ពុំឲ្យនាងនៅ ៗ      នាងរងអៀនអន់      ពង់ពោះស្រីតន់
រំជួលក្តាត់ក្តៅ      ល្អះល្អាចពេកក្រៃ      ហឫទ័យហ្មងសៅ
ខំបន្ទូលទៅ      ទាំងទាល់ច្នេះថា ៗ      ហៃប្អូនស្រស់ស្រិល
នាងទាំងប្រាំពីរ      ស្តែងស្តាប់សិនព      បង់ឥតទោសទេ
កុំមេគ្រោធា      ប្រោសបង់ឃ្លាតឃ្លា      ប្រការគល់អ្វី ៗ
បង់សោតសូមឈប់      ដ្បិតពន់ប្រលប់      ជួបចូលពត្រី
ទំពំព្រឹក្សព្រាង      ស្រាងឧណោទ័យ      បង់ចេញខ្លី
កុំព្រួយនាងថា ៗ      ឯព្រះភូមិន      ដៃដេតចក្រ
លុះត្រាវ៉ាជា      បរិបូណ៌មិនមាន      គ្រេមក្សាន្តចិត្តា
រង់ក្រេវក្រោធា      ទឹងនាងនារី ៗ      រង់ស្អប់រង់ម្នេញ
បន្ទូលបន្តេញ      ចូលហាងណាលី      ចរចេញឲ្យឆាប់
ប្រញាប់ម្នាម្នី      ហាងនៅហើយដី      វិតមិងមរនា ៗ
នាងនាថស្រីថ្ងៃ      រង់វិតគិតកៃ      ខ្លាចព្រះចេស្តា

| | | |
|---|---|---|
| ពុំហ៊ានដំអឹង | ទទឹងអាជ្ញា | ទ្រង់ព្រះបិតា |
| នឹកក្តុងហឫទ័យ ៗ | ឲអស្ចារ្យស្រល់ | នឹងព្រះទសពល |
| ផ្ទែកក្រៅវិសែ | សំត្រូវកល់ស្នែ | អស់មេនោះនែ |
| អាចឲ្យក្សត្រថ្ងៃ | វង្វេងសោះសា ៗ | បើអញរបឹង |
| រឹងរូសទទឹង | ពុំទៅឡើយណា | សំអញក្សិនក្ស័យ |
| ប្រៃឡែដន្ទា | ប្រាកដកាលគ្រា | ឥឡូវនេះម្តង ៗ |
| ហើយវរដេយ្យា | ទួញទូលលាតលា | ព្រះបាទព្រះបាង |
| ព្រះសើយស្តេចនៅ | ខ្ញុំទៅហើយហោង | កម្មខ្ញុំ ៗ រង |
| ទុក្ខតាមវេក ៗ | ក្សិនក្សត្រីថ្ងៃ | បរបុះឃាតខ្ទី |
| យាងយាសយាត្រា | ដល់នេតសស្រាក់ | ស្រោចស្របក្ត្រា |
| ជ្រុះសឹងចម្ប៉ា | មាសមានដំឡៃ ៗ | នាងចយាត្រា |
| តែនឹងវិឡា | ដិតដោយក្សត្រី | កាលនោះសោតណា |
| ទាសាទាសី | សោយសោកពេកក្រៃ | អាណិតក្សត្រី ៗ |
| ខ្លះរត្តូរត់តាម | ទឹកភ្នែករហាម | ពេបមាត់វែងខ្វី |
| ខ្លះគកឌុក | ថាម្ចាស់សិរសី | ឃ្លាតបាកបុរី |
| ខ្ញុំសូមទៅផង ៗ | នាងបន្ទូលថា | គំបីអស់គ្នា |
| តាមទៅឡើយហោង | ហេតុកម្មអញឯង | ពីព្រេងចាំចង |
| ចូលរិលវែងផ្គង | កុំតាមឡើយណា ៗ | អស់ទាំងទាសី |
| លុះព្រុសំដី | នាងនាថថ្ងៃថ្វា | ពុំហ៊ានតាមទៅ |

ឈប់នៅវេហា ទុញទាល់ទុក្ខា ដោយនឹកអាល័យ ៗ ខ្វះយំថ្ងូរថា

ឱម្ចាស់សិរសា ចាកចោលយើងនៃ យើងខ្ញុំកំព្រា
ព្រួញប្រាណាពេកក្រៃ សមខានយល់ថ្ងៃ ថ្ងៃនេះហើយណា ៗ
ខ្វះថាឱម្ចាស់ មិនគួរបើប្រាស ព្រាត់យើងពល់គ្នា
ពីថ្ងៃនេះទៅ នឹងបានអ្នកណា ដូចម្ចាស់សិរសា
ព្រះទ័យល្អក្រៃ ៗ ហើយអស់ទាសា បបួលគ្នីគ្នា
រើសបំប៉ាវ ដែលជ្រុះពីឱស្ឋ ដោមស្រស់សុវណ៌
តាមមាគាព្រៃ បានហើយថ្ងូរថា ឱយើងខ្ញុំយល់
ផ្កានេះល្អសល់ ពីព្រះឱស្ឋ ផ្អិនផ្អៅសោភាន់
សុវណ្ណបំប៉ា ភ្ជិនដូចធីតា ឈ្ងុយឈ្ងប់ល្អបល្អង
ឱធំភ្ជិនដែល ប្រហើរប្រហែល ស្រីស្រស់ប្រិះប្រៀង
ហាក់បានយល់អង្គ ផូផង់ម៉ត់ម៉ង់ ពិដោកន្ទង
ដាងអស់បុប្ផា ៗ កាលនោះអស់ស្រី វិលវឹងមកខ្ញី
លំនៅអាត្មា រង់ទុក្ខពុំក្សាន្ត មែនមានចិន្តា
អាឡៃដេយ្យា ប្រសើរសួស្តី ៗ

## បទព្រំគិត

យើងនៅទិទានពី វរក្សត្រសុវណ្ណា
នាងត្រៃបទឹងវិឡ្យា ពិតពុំដឹងទីដម្បូន់

ហើយនាងរិះគិតថា ព្រះមាតាទ្រង់ពុំទាន់
ជ្រាបហេតុត្រូវស្រពន់ ទៅទូលឲ្យជ្រាបសេចក្ដី ។
វិទ្យាព្រមនាងនាថ ត្រេបសង្វាតបរបូលខ្ចី
កាលនោះអស់ទាសី របស់នាងសព្វឯកា ។
តែងតាមមើលបំណាំ រត់ស្រាំឈរវេក
ស្ដីត្រែគោះទៅថា រិះរកពនមកមិនខ្លាច ។
បំបរបង់បន្ដេញ វិលមកវិញអាងអំណាច
បបេសនៅមិនខ្លាច ខ្ទួនទឹងខ្សែនៃដន្ទា ។
បួរបេញ ៗ ទៅធាប់ នៅទឹងស្លាប់
ឥឡូវនោះណា យើងទូលព្រះពជា
ពិតពុំរស់រួចជីវិ ។ នាងស្ដាប់ហើយនាងខ្លាច
ពិតពំអាចចូលទៅខ្ចី ខំលោមមេទាសី
ថាហៃនាងសូមមេត្តា ។ នាងឲ្យអញទៅដល់
ព្រះទសពលពីរអគ្គា ឲ្យជ្រាបហើយអញលា
ពីរព្រះអង្គបរបេញហោង ៗ ទាសារង់ខឹងខំ ថានាងកុំចូលនេះម្ដង
យើងទូលហើយយល់ឆ្គង ពុំលែងឡើយលុះនៅខ្សែ ។
នាងស្ដាប់អស់មេនោះ ក្រោធទ្រគោះពន់ពេកក្រៃ
នាងនាថកាំងកិតកៃ ហើយនាងវិលវិញយាត្រា ។
នាងចូលក្នុងព្រៃព្រឹក្ស ទួញសន្ទឹកសោយសោក្កា

ទុបាបុត្តពុំភារ　　បាត់ពំយល់កាលនោះម្តង ៗ
ស្ងួនឡើយទោះក្រោយ　　ទុក្ខទាំងឡាយម្តេច ៗ ហោង
លែងបាបុត្តស្ងួនគ្រង　　មាសបូលមករកម្តាយព ៗ
គ្រាន់បានយល់មុខអ្នក　　ថ្ងៃរលាក់តាំងបិតា
ឲ្យម្តាយល្ហែទុក្ខា　　សោះសោយសោកសល់សែនធ្វី ៗ
ស្ងួនឡើយបើជ្រាបដល់　　ព្រះទសពលក្រុងកាសុរី
សំស្តេចក្រេវក្រោធក្រៃ　　ពុំប្រណីយកទោសា ៗ
ប្រើអស់ពួកយក្ខយុង　　ចោមចាប់អគ្គបីតាបា
ហើយនូវក្រុងភាព　　នឹងវិនាសកាលនោះម្តង
ម្តាយនឹងគិតប្រណី　　ដល់ព្រះបីតាបាហោង ៗ
ក្រែងពុំប្រែរម្ងង　　ពីទុក្ខទោសព្រោះអាសុភ ៗ
ម្តាយគិត ៗ បម្រែង　　ដូចគេដែងដេកឧក
ហាក់ពុំមូលនូវគ្នា　　ក្រិក្រក្រៃនឹងទុកដាក់ ៗ
ក្របើនឹងទូលពិត　　ក្រមួយឥតបើនឹងលាក់
តែងតោងជាប់ជំពាក់　　ជំពិនពេកពុំដឹងបើ ៗ
នឹងស្មៀមនឹងបាត់មាត់　　យល់ពុំស្ទាត់អស់អំពើ
ពិដឹងរកកលធ្វើ　　ម្តេចឲ្យបានសុខឡើយហោង ៗ
កាលនោះឯវិឡា　　យល់ធីតាសោកកន្ទួង
ទួញទៅបុត្រស្នែស្នង　　វិឡាលួងលោមទៅថា ៗ

អ្នកមាសថ្លៃឧត្តម អ្នកកុំយំសោកបុត្រា
នាងខ្ញុំទឹងធានា នាំទៅរកបុត្រពីសី ។
ដ្បិតខ្ញុំបានយុងយល់ ដោយកិច្ចកលអស់មេស្រី
ប្រាំពីរកេន្តី កាលបំពត់ពងបុត្រា ។
ពដាក់ទឹងហិបស្រេច ហើយនាំត្រេចត្រង់ព្រឹក្ស
ទៅកប់បុត្តពំងា ក្រោមនិគ្រោធមួយធំសល់ ។
ខ្ញុំតាមលងលួចមើល ដឹងដំណើរនូវកិច្ចកល់
ហើយខ្ញុំបានសំគាល់ នាទីស្ថាននោះជៀងជាក់ ។
នាងស្ដាប់វិទ្យាស្ដី វរក្សត្រីត្រីព្រួចភ្ញាក់
អរឯងឥតទុកដាក់ បន្ទូលទៅថ្កានវិទ្យា ។
នាងងើយបួលនាំបង ទៅនេះម្ដងឆាប់រួសរា
អាសូរបុត្រពំងា យូរក្រែងខ្សែជន្មជីវ៍ ។
វិទ្យានាំនាងនាថ ត្រេចគគាតខំខ្វាតខ្វី
ដើរដោយថ្នល់ទួលទី រុករកពងបុត្រពំងា ។
វះផ្លូវវិមពមសល់ រកពុំយល់និគ្រោធា
ដែលកប់នៃព្រះមហា អគ្គសារពេជពុំទន្ទូល ។
ពីរប្រាណខំយាត្រា កាត់ព្រឹក្សាឆ្លងចេញចូល
វិទ្យាវែងទឹកធ្ងស់ ដោយពុំយល់ដូចបំណង ។
ឯនាងនាថស្រីថ្លៃ វិងកិតកៃក្រែកន្ទុង

ទុញទល់ទុក្ខទៀតហោង　　អួលអាណិតអាណាថា ។
កូនអើយម្ដាយលំបាក　　ដើររកអ្នកមាសពំនារ
អស់កលពំយល់ជា　　បុត្របណ្ដូលថ្លើមចិត្តនាយ ។
ជាបម្ដាយអ៊ូដល់ម៉ឹង　　ទ្រូងតាន់តឹងស្ទើនឹងធ្លាយ
ទុស្សន ៗ នោមឆាយ　　ព្រាត់ពីកាយដូច្នេះណា ។
ម្ដាយពុំទាន់យល់មាស　　ម្ដេចមកប្រាស់ព្រាត់អាសារ
ឯកោកន្ទអត្ថា　　សំវេទនាឫក្សណាក្សយ ។
ឱកូនកែវវរលក្ខ　　ក្រែងអារក្សទេព្រ័ក្សព្រៃ
បំបាំងបាបុត្រថ្ងៃ　　ពិតពុំឲ្យយល់នេះម្ដង ។
ក្សេណ្ណោះវរជាយា　　នាងសង្វាបទួលផ្សង
បពិតទេព្រក្សត្រផង　　ដែលរក្សាព្រះព្រៃព្រឹក្ស ។
ទោះតាំងទេពសោឡ្វោះ　　សួគិត្តខ្ទង់ខ្ទស់ ៗ ពន្ទឹក
អ្នកកើយអញខ្ញុំទឹក　　អាទិស្ថានកាលនេះម្ដង ។
ដ្បិតខ្ញុំមានទុក្ខក្រៃ　　សូមអ្នកនាំអញខ្ញុំផង
ឲ្យយល់កូនសួនគ្រង　　ដូចចិត្តខ្ញុំប៉ងប្រាថ្នា ។
នាងផ្សងស្រែបជូនថៃ　　ក្សេណ្ណោះឯនាងវិទ្យា
គំបន់អស់ទេព្តា　　ថាបពិតទេពថ្វាថ្ងៃ ។
បើអ្នកនាំឲ្យយល់　　បុត្រនិមលកាលនេះនៃ
គុណអ្នកនោះធ្ងន់ក្រៃ　　ខ្ញុំនៅសងគុណអ្នកណា ។

ខ្ញុំឯងកាប់ប៉ាំ    ខ្ញុំនឹងពាំថ្វាយទៅ
ប្រាកដពុំមោសា    សូមអ្នកជួយកាលនេះហោង ៗ
កាលនោះហេតុបារមី    វរក្សត្រីថ្ងៃប្រះប្រង
រំជួលទេព្វតាផង    នាំបង្ហាញបុត្រពីសី ៗ
វិទ្យាយុងយល់ស្ពាន    ទីដែនដានអរអស់ក្តី
បូលហ្កានទិគ្រោធខ្ទី    រួបស្រមាស់ស្រមាប់ផង ៗ
នាងនាថបរបូលជិត    យុំអាណិតបុត្រវរវង្ស
ស្រយុតស្រយាកអង្គ    ទៀបទល់ក្បែរជន្ទដីរី ៗ
តេជៈហេតុសក្កា    រាជកុមារថ្ងៃពីសី
បំណោរជាជិនស្រី    គឺសម្មាសម្ពុទ្ធប្រាសាំ
ក្យណ្ណោះវីធទី    ដោយបារមីហាក់បម្រែះ
របើកបែករយះ    ផុសទាំងហិបចេញមកខ្ទី ៗ

## បទកាក

នាងបើកហិបបាន    យល់បុត្រកល្យាណ    ល្អល្អះប្រពៃ
យល់ទាំងព្រះខាន់    កៅទាន់សរដៃ    ព្រះម្កុដមាសមៃ
កម្រាលបុត្រា ៗ    សង្ហាកកង    អន្ទាមសូរង
កន្ទុលទេព្វា    ភ្ញីផ្ទុកប្រាសប្រាល    រន្ទាលថ្ងៃថ្វា
បែងចាំងអង្គា    ត្រចះព្រោងព្រាយ ៗ    នាងអរឱបបុត្រ

ប្រានប្រុសពិសុទ្ធ គៀកកិតព្រះកាយ ថើបថៃអស់អង្គ
ប្រតិយ៉ន់ឆោមឆាយ ប្រលឹងមាសម្ដាយ ម្ដាយអរក្ដាត់ណា ។
ឱស្ងួនត្រកាល ស្ងួតសាប់សង្វា ថ្ងើមថ្ងៃពាំងា
ល្អដូចន្ទពូគុណ ទិព្វតនសោភា ម្ដាយយល់មុខបា
បណ្ដូលហឫទ័យ ។ ស្ទើយល់ព្រះភក្ត្រ ព្រះបីតានាក់
មាសមិត្តនោះនៃ ទុក្ខម្ដាយគ្រាន់ស្បើយ គ្រាន់ល្ហើយហឫទ័យ
តែនៅថប់ក្រៃ នឹងព្រះបីតា ។ ឱកូនមាសថ្ងៃ
ទោះម្ដាយក្បិនក្សយ លែងមួលនឹងបា អាសូរកំសត់
ទូរគគកំព្រា ព្រាត់ព្រះបីតា ពីតូចក្ដាត់ហោង ។
ម្ដាយឥតស្ដុកា អ្វីជាត្រកាល ចង់ដៃស្ងួនគ្រង
មានតែព្រះទុំរង បញ្ចាង់ឥតហ្តង ចង់ដៃបារហោង
ឥឡូវនេះណា ។ ប្រសិននៅស្រុក មួលមួយដំនុក
ឮយគោឮយកា តាំងបីទសពល បានយល់មុខបា
សំស្ដេចករុណា មិនឲ្យមានផ្គង ។ កិលៀងមេនុំ
អកយាយចាស់ទុំ រួមរក្សាគ្រង បំពេប្រួបដៀង
សូរសៀងរំពង ថ្នាក់ថ្នមត្រកង បុត្រស្ងួនសង្វា ។
ឥឡូវនេះម្ដាយ ឯកឯងនៅអាយ ត្រមោចកំព្រា
ម្ដាយនៅក្នុងទុក្ខ ឥតសុខឡើយណា ទឹងបានអ្វីជា
សម្រាប់បុត្រហោង ។ អ្នកមាសផ្អិនផ្អៅ កូនន្ទីយបារបៅ

ឲ្យផ្អែតនេះម្ដង  កម្ឯងឲ្យចាក  លះលាក់បង្គង
អាចឲ្យយើងវង  ទុក្ខទោមនស្សា ។  ម្ដាយរង់ប្រណី
កូនកែវពីសី  បណ្ដូលស្នេហា  ម្ទុះទឹងហ្មងសៅ
កំដៅសុរិយា  ត្រូវត្រង់អង្គា  ស្រពោនកន្ទង់ ។
កាលនោះវិទ្យា  ថើបថៃបាទា  រាជបុត្រស្នេស្នង
អ្នកមាសពំនារ  កំព្រាឯកអង្គ  ត្រកាលជាច្បង
លើសលើលោកា ។  ល្អម្ដេចអម្បាយ  អស់អង្គទ្រង់ព្រាយ
ប្រហែលបីតា  ទ្រង់ព្រះនរលាក់  ព្រះកក្ដ្រជ្រះថ្លា
ឥតខុសត្រង់ណា  ទឹងចិត្តខ្ញុំនៃ ។  ក្សណ្ណោះធីតា
នាងសុវណ្ណា  បន្ទូលថាហៃ  នាងបញ្ចរ
ពុំងាថ្ងើមថ្ងៃ  គុណគាប់ក្រាស់ក្រៃ  ក្រឥងគណនា ។
អង្គសំបុត្រ  ក្សណាកែ្សប្រាកដ  កណ្ដាលអធ្វា
ឥតអ្នកទូវយល់  កិច្ចកលកាផ្ឈា  នាងស្មើបីតា
បង្កើតកូនថ្ងៃ ។  ឥឡូវយើងបាន  យល់កូនកល្យិយាន
រស់រួចពុំក្រៃ  ហើយយើងនឹងទៅ  លំនៅវិញនៃ
រិះរិងចប់ក្រៃ  ក្រកាត់ស្នេហា ។  បើយើងនឹងទៅ
ព្រះបីតាចៅ  សឹងហុនការ  អាសូរកូនស្ងួន
ខ្ញុំមខ្លួនពំនា  ដើរដោយអធ្វា  លំបាកឥតបី ។
សឹងខ្មោចបីសាច  រាជកូតផងក្ងាច  ផ្ដន្ទាយាយី

ហើយហាលថ្ងៃក្ដៅ ហួនសៅសំបី នៅកើតព្យាធី
ជម្ងឺរោគា ៗ មួយបើយើងនឹង ត្រឡប់វិលវិញ
ព្រះរៀមរាជា ម្ដេចឡើយព្រះអង្គ នឹងទ្រង់ករុណា
កាលក្រេវក្រោធា វង្វេងក្ដាត់ហោង ៗ សំត្រូវកលគេ
មែនមានមិនទេ ប្ញូកក្រែកទ្រូង ទៅហើយសំកៀរ
ប្រែខ្សែនេះម្ដង ក្រៃក្រក្ដាត់ហោង អស់ឯងពីក្ដី ៗ
កាលនោះវិទ្យា សាសង់ទូលថា បពិត្រក្សត្រី
បើនាងនឹងទៅ ហោមហៅអាសុរី ខ្ញុំសោតឥតបី
ទទឹងឡើយណា ៗ បើទៅព្រះបង់ ខ្ញុំយល់ថាធ្គង
មិនដូចសព្វគ្រា ស្ដេចត្រូវកលគេ ឲ្យប្រែចិន្ដា
ស្រឡាញ់តែជា ប្រាំពីរនោះនៃ ៗ ល្គិកបើពុំអត់
ស្ដេចឲ្យធ្វើគត់ ពិឃាដក្សិណក្ស័យ អាសោចអាសារ
ឥតការទេនៃ ព្រះបីតាថ្ងៃ ពុំជោបទេយ្យា ៗ
មួយបុត្រឧត្ដម ជាទេអ្នកកុំ ព្រួយព្រះចិន្ដា
ទោះទាំងព្រះបង់ ទ្រង់ជោបកាលណា ទៅមូលនឹងគ្នា
ប្រាកដក្ដាត់ហោង ៗ នាងស្ដាប់សំដី ពាក្យវិទ្យាស្ដី
បែងបះសាសង់ នាងបន្ទូលថា វិទ្យានេះម្ដង
យល់គាប់ក្ដាត់យោង ដូចពាក្យនាងថា ៗ បើច្នេះយើងទៅ
ព្រះបីតាហៅ ហោមពង្សយក្សា នាងនើយស្ដាយពេក

| | | |
|---|---|---|
| អស់ឯកចិន្ដា | ពិតពុំមូលគ្នា | ស្អាក់ស្មើចម្បែង ៗ |
| បន្ទូលបោះនៃ | អួលអន់អាឡៃ | ព្រះនេត្រហូរហូង |
| ននៀលច្រាស់ច្រាន | អន្ទះអន្ទែង | ទ្រង់ព្រះកន្សែង |
| សោយសោកាក្រែ ៗ | ព្រះសើយប្អូនលា | ប្អូនឥតអ្វីជា |
| កស្ដុតាប្រែពៃ | មានតែបូជា | ចម្ប៉ាមាសមៃ |
| ពីព្រះឱស្ថថ្ងៃ | ទុកតាំងអាត្មា | ក្រែងព្រះពន្ទុក |
| ស្ដែងស្ដេចត្រេចរក | រៀងដោយមាតា | ពុំបានយល់អង្គ |
| បោះបង់ឃ្លាតឃ្លា | យល់តែបូជា | គ្រាន់ស្រានអាឡោះ ៗ |
| ព្រះមាសឧត្ដម | ជាទីងនាំខ្ញុំ | ចរដួនផ្ទុកផ្ទោះ |
| សួរព្រះបីតា | មាតាខ្ញុំនោះ | ឥឡូវម្ដេចបោះ |
| បង់សៀតស្ងួនសល់ ៗ | ព្រះសើយប្អូនទៅ | តាំងទុក្ខគាត់ក្ដៅ |
| អួលអន់អំពល់ | អំពើកម្មកាយ | ព្រេងនាយមកផ្ដល់ |
| ផ្ដាច់ឲ្យប្អូនទល់ | ទុក្ខធ្ងន់សោកា ៗ | ព្រះមាសឧត្ដម |
| កំសត់ទីងខ្ញុំ | ពីមុនមិញណា | កាលកំពានយក្ខ |
| អប្បល័កនោះវា | ដេញដំពជា | អង្គីសំក្រៃ ៗ |
| ប្អូនឲ្យពិភាក | សូទគ្រងរួមពក់ | រស់រួចពីភ័យ |
| បានជួបជាគូ | នៃបនៅមូលមៃ | ព្រះបីតាថ្លៃ |
| ទ្រង់ព្រះករុណា ៗ | ខុសគាប់គួរអត់ | គិតកាលកំសត់ |
| កុំយកទោសា | ម្ដេចជឿពាក្យគេ | ស្រាយស្រែមាយា |

នេះសំរេច ខ្ញុំឯងក្រាស់ក្រៃ ៗ ពីដួចប្អូនបាន
មូលមួយរួមស្ថាន ព្រះមាសមហាថ្ងៃ ពុំដែលឲ្យអាក់
ថ្នាំងថ្នាក់ព្រះទ័យ លុះគ្រានេះនៃ និពស្ត្រចាកឆ្ងាយ ៗ
ឲជាតិនេះខ្ញុំ ប្រាស់ព្រះបរម ននាថពន្រាយ
សូមសព្វជាតិក្រោយ កុំឲ្យឃ្លាតឆ្ងាយ នៃបទិត្យរួមកាយ
ជាគូស្នេហា ៗ នាងទួញសព្វគ្រប់ ប្រាស់ប្រានសន្ទប់
ក្រោមដើមព្រឹក្សា ពុំភ្ញាភ្ញាក់អង្គ យូរលង់ក្ដាត់ណា
ឯបញ្ចាព កែកិតឯងសល់ ៗ បូលជាស់ទាញទង់
រង្គីអស់អង្គ នៃនាងនិមល សៀមស្ងាត់ជ្រងុំ
ពិតពុំភ្ញាក់ដល់ តិបឡើយរងទុល ទុកទៀងទួញថា ៗ
អម្ចាស់បុណ្យច្រើន អញ្ជើញគោះឡើង បំបៅបុត្រា
បើសៀមសូន្យសោភៈ អត់ដោះប្ចេះណា នឹងបានក្សីណា
គ្រាន់បៅសោះឃ្លាន ៗ វិឡ្យារិងយុំ តានតឹងក្រៀមក្រំ
ទល់ទប់ពុំបាន ដល់ដួលសន្ទប់ ចំប្រែបនាស្ថាន
ហេតុផ្សិតដោយមាន ប្រណីបុត្រា ៗ កាលនោះឯអង្គ
ត្រកូលពូជពង្ស រាជនរស្សា អ្នកនឹងបានត្រាស់
ប្លាស់ប្លងលោកា នាំសត្វសង្ខ្យា ជាក់ដល់ត្រើយហោង ៗ
លុះព្រះមាតា នៅនាងវិឡ្សា សន្ទប់ជាម្ដង
ទ្រង់ព្រះបិត្ដា សច្ចាសូមផ្សង អស់ទេពប្រាក់ផង

កាលនោះឯងណា ៗ បពិតទេព្រាក់ រិនរិទ្ធិសក្តិ
នូវទេពទេវ សូមអ្នកស្តែងស្តាប់ សាសព្ទសព្វា
អញខ្ញុំកាលត្រា ឥឡូវនេះនៃ ៗ បើខ្ញុំនូវបាន
ត្រាស់ពោធិញាណ អនាគតនៃ ឥឡូវមាតា
សោភាប្រពៃ សន្ទប់ក្សិណក្ស័យ នូវនាងវិទ្យា ៗ
សូមទេព្យតាំងនោះ ជ្រោមជ្រែងជួយដោះ ទុក្ខខ្ញុំនេះណា
ឲ្យព្រះជិនី ក្សត្រីថ្លៃថ្លា នូវនាងវិទ្យា
ភ្ញាភ្ញាក់ស្មារតី ៗ អ្នកផ្សងតែម្ល៉ោះ ពួកកាលនោះ
ហេតុព្រះបារមី កក្រើកសក្កោ ទេវាធិបតិ
ស្តេចហោះចុះខ្ចី ដល់ដែនកស្យផ ៗ យកគន្ធីអប់
ទឹកទិព្វត្រឡប់ ស្រោចស្រប់ដោយ្យា នូវវិទ្យារី
ដោយក្តីមេតា នាងភ្ញាក់អង្គ៉ា អាលជស់ឡើងថ្វាត់ ៗ
ក្សិណព្រះសក្កោ ទិព្វទេពទេវ អន្តរធានបាត់
ហៀវហោះវិលថ្កាន វិមានរុំរត ក្រេមក្សាន្តសល់ក្តាត់
នូវស្នំស្នេហា ៗ ឯអង្គក្សត្រី ប្រសើរស្រស់ស្រី
នឹងនាងវិទ្យា ពុំក្បែព្រះជន្ម ស្រីតនឡើយណា
ដោយបុណ្យបុត្រា ជួយជូននាងហោង ៗ នាងអាទុនទុប
ថ្នាក់ថ្នមក្រសោប បុត្រាស្នេស្នង ថើបព្រះកត្រា
ចរចារសាសង សន្ទើយនេះម្តង ម្តាយក្បែជន្មា ៗ

ហេតុម្តេចឡើយបាន  រស់រូបវិញ្ញាណ  នេះសំបុណ្យបា
ជួយជនជីវិត  ឯងឥតសង្កា  មាសម្តាយ ៗ មហា
អរក្រៃកន្ទួង ៗ  នាងនាថឥតសៅ  បីបុត្របំបៅ
ឥតឯមានហ្នង  ពុំលុងឡើយណា  វិទ្យាឯងហោង
ក្រួញក្រាបទូលស្នង  ព្រះពជពន្ទិតា ៗ  បពិតយូរលុង
អញ្ជើញព្រះអង្គ  ស្តែងស្តេចលីលា  ចរត្រេចដម្រង់
សឹងហុនពជា  អាសូរបុត្រក្ងា  ថ្ងើមថ្ងៃកល្យាណ ៗ
បើនៅលង់ក្តាត់  ក្រែងកើតដម្កាត់  ព្យាធិពុំក្យាន
នាងស្តាប់វិទ្យា  ចរចាសងសារ  នោះនាងកល្យាណ
ព្រមព្រះចិន្តា ៗ  ស្រាបស្រេចពុំ.បុង  នាងនាថវរវង្ស
បីបុត្តពុំងារ  ហើយនាងអង្វរ  អស់ទេពទេព
អធិដ្ឋានលា  នាងទឹងចេញចរ ៗ  បពិតទេព្តា
ទាំងជកាមា  នៅព្រឹក្សក  សូមអ្នកនាំនា
យោគ្រាឲ្យបរ  បូរជល់នគរ  សឹងហុនបីតា ៗ
ហើយឲ្យខ្ញុំបាន  មូលទឹងក្សត្រក្បាន្ត  គម្តែងក្រឡា
ខ្ញុំរៀបប្រជាប់  ឆាប់ ៗ ដូចថា  ភ្ញីផ្កាបូជា
ពុំឃ្លាតឡើយហោង ៗ  រឹងវិទ្យា  សឹងបែបបទ់ថា
ពាក្យពេជឥតគួង  បើបានដូចចិត្ត  យើងគិតប៉ុនប៉ង
អស់ពាក្យពេជផង  ពុំភ្លេចឡើយណា ៗ  ហើយក្សត្រីថ្ងៃ

ចរចាកឃ្មាតឃ្មៃ　និគ្រោធព្រឹក្សា　នាងពរភជបុត្រ
ពិសុទ្ធស្នេហា　ឯបញ្ញព　នាំនាងចរខ្វី ៗ

## បទភុជង្គ

ស្រីថ្ងៃដើរព្រៃព្រឹក្សា　ស្បូវស្វាតបន្ទា
ញញ្ញារញៀតញឹក ៗ　ព្រះទ័យមៃ ៗ សន្ធឹក
ផ្អូកផ្អេះរលឹកព្រះរៀមរាជា ៗ　សៅហ្មងតុះតង់បាទា
រអាមរអាសផ្គៀកក្រំក្រៃ ៗ　នាងនាថលេចរាលចូលព្រៃ
នឿយណាស់ល្ហិតល្ហៃស្រពោនកត្ត្រា　ព្រៃព្រឹក្សស្មោមស្ងំក្រុខា
លូតលាស់ផ្លែផ្កាលន្ទុនទន្ទន់ ៗ　ពាលព្រេចលាយលេចដើមដង
សុក្រំក្រួចបងសក់សេមាន់មៀន ៗ　មាំងឃុតរមុតទូរេន
សេដៅម៉ាក់ព្រេងម៉ាក់ប្រាង់បេកផេះ　ក្តាំង៉ោកតិកាកាកេះ
បេកទុំបេកទេសល្អបល្អងកេសសរ ៗ　រំចាករំបេកគុយគ
ទាំងឪទម្ពរពេលស្រឡៅ ៗ　ត្រាចត្រសក់កោះព្រះក្នៅ
មរុំម្រះព្រៅពោនពោផ្អាវផ្អង ៗ　ក្រៀលក្រពង្រុករុង
ដៃខ្លាក្លែងគង់ឪលោកលាំងលៀប ៗ　នាងទ្រួនក្រញូងបង្ក្រាប
ចាន់ចារដើងចាបឪដ្រឹងដែរដ្រែ ៗ　ដកពរដកពាយទូរផ្កែ
ស្រែងស្រល់អន្ទ្រអង្កោលអង្កាញ់ ៗ　ផ្តៀកផ្តៅតាត្រៅប៉ផិញ
គគីត្រឡាញ់ត្រឡាតត្រឡក់ ៗ　ស្តីស្តៅបង្គៅសម្រែក

សម្រាមចំបក់ស្ទុតស្តៅដែរប្រេះ ។ នាងយល់ទួញទល់ទង់គិះ
ក្រឹកក្រលផ្អូកផ្អិះសែនសោយសោកា ។ ដើរដល់នាច្នេដលសា
ទិករង់ជ្រះថ្លាជម្រាលត្បូងខ្សែច ។ បក្សាវេកាហើរហិច
ចាបព្រាបប្រពេចត្រដៀវរិចលរយ ។ ទោមទុងសំកុងវៀនពយ
ហិចហែលប្រញាប់លលើលើនៃកែ ។ មាន់ទោមាន់ទឹកមាន់ព្រៃ
បចាតប្រវៃប្រឡំកាសា ។ ក្អែកទឹកប្រវិតទទាទទាស់បក្ខាទន្សាបទិមទុំ ។
រលកហើមកប្រជុំ    ទាំងតួយាសយុំស្ទូរសត្វរមួង ។
សៀនក្បៀនដើងទៀនត្រយង    គ្រៀលចង្អៀលខ្សែងលោតដេញចង្វា ។
ស្ទិតចៅតាពើសារិកា    រំពេច្ឆេត្ធាហើរស្កាត់រកត្រី ។
កុកគ្រានកុកក្រកវៃព    ស្ទាំងស្ទុះហើរវៃកណ្ដាលកេក្រាម្ចា ។
មើលអកសំកុកទូវនា    ចាំចាប់មច្ឆាឆាបឆក់ហើរទៅ ។
ត្របៀកកាំៈហើរស្ទុងស្ទៅ    ក្ងោករកនៅសំដីងនុក្ដី ។
កដបបទាវឈ្នោលញី    ពាំកស្ដុចំណីប្រចុកកូនវា ។
មើលទៅហាក់ដូចព្រះមហា    បពិតករុណាវែងថ្មមប្អូនស្រី ។
សោយផលសុកលប្រក្រតី    ស្និតស្នាលៈបតីសំណេះបរបារ ។
ក្អែកទឹកស្មោញខំមហិមា    មុចប្រែកគគ្នាក្របាមអស់ក្អែក ។
ក្អែកគោកហើរមកហើយស្រែក    ទៀវទីទុយខ្វកសកសៀតពូនពង ។
កុងព្រៃសត្វរែកន្តង    ស្រែកចៀនទ្រហ៊ុងស្រង៉ាត់អគ្វា ។
ខាងស្តាប់សាសត្ថៈទោះណា    ព្រយព្រះទេយ្យាគិតដល់ជនី ។

ដោរដលនេត្រសោតសែនថ្លី ដើរដោយទ្លួលទីចូលបតស្រះស្រង់ ៗ
ស្រីថ្ងៃប្រពៃវរវង្ស ចរចុះទៅផ្គងផ្តួតទឹកបុត្រា ៗ
រូបស្រេចសម្តេចដេយ្យា គង់ម្លុបព្រឹក្សាល្ហិតល្ហៃត្រដាក់ ៗ
ព្រះពាយផាត់ផាយត្រសៀក ស្រីស្រស់វរលក្ខបំពៅបុត្រក្សា ៗ
នាងខ្វាចអស់សត្វអម្រិគ្គា ពុំអាចចរចាសៀមស្ងាត់ទាំងថ្លី ៗ
តេជះហេតុបុណ្យបារមី ពន្ទុកជិនស្រីលើសលើលោកា ៗ
ត្តៅដល់មន្ទល់អាស្មា សម្តេចឥន្ទ្រាចោមចៅធិបតី ៗ
ប្បុតស្រេចស្រុតមកខ្ញី ដល់មន្ទល់ទ័នាងនាថថ្វាថ្ងៃ ៗ
និម្មិតពជវង្គអាជាន័យ ល្អល្អះប្រពៃថ្វាយនាងដេយ្យា ៗ
នាងយល់អរសល់ក្តាត់ណា បីបុត្រស្នេហាឡើងលើរតថ្ងៃ ៗ
ទេព្តានាំនាងឃ្មាតខ្ញី ជម្រង់ទៅពួសឹងហុនសេម្ពា ៗ

## បទកាក

| | | |
|---|---|---|
| កាលក្រោយក្សត្រី | ចេញចាកបុរី | ដៃដេតក្សត្រា |
| តើនចាកបន្ទុំ | សក្តិសំសោភា | ប្រដាប់អាត្មា |
| ស្តែងស្តេចទៅប្កាន ៗ | ឡើងគាល់បីតា | ទូវនាងសប្តា |
| ទៅប្រធាន | បង្គំវន្ទា | ទ្វេហាក្សត្រក្សាន |
| យល់បុត្រកល្យាណា | ត្រេកសោមនស្សា ៗ | មានព្រះជម្រាស់ |
| សាសងត្រេកត្រាស់ | ជន្តំងមីមា | ហៃស្ងួនត្រកាល |

សង្ក្រស្នេហា ទៅទាក់គូផ្គួសា តើម្ដេចស្ងួនណើយ ៗ
ឯព្រះរាជបុត្រ ទុនអង្គលំអុត ប្រណម្យក្រកាយ
ទើបទូលក្សត្រា ថ្លៃថ្លាពន្រាយ អស់អត្តិប្រាយ
សូមទ្រង់ករុណា ៗ សូមទានខ្ញុំទៅ ដូចដល់ព្រៃជ្រៅ
ខេត្តខាន់អង្វា ក្រសព្វទិសទី គិរីបព្វតា
ជ្រុងជ្រោយនា ៗ ពិតពុំបានយល់ ៗ ខះខំពេកក្រៃ រករសាយដៃ
ដោយព្រៃទីទួល អស់ចិត្តពុំបាន វិលឋានមណ្ឌល
សូមព្រះទសពល ស្ដេចទ្រង់ករុណា ៗ មួយសូមព្រះបាទ
ព្រះបរមនាថ ជ្រាបព្រះទេយ្យា ដ្វាតក្រោយខ្ញុំទៅ
ព្រៃជ្រៅអង្វា នាងសុវណ្ណា ជាខ្ញុំនៅអាយ ៗ
បង្កើតទទបាទ ពុំត្រូវទឹងខ្នាត ច្បាប់បូរាណនាយ
ឈើផ្លែសម្រាល រាជបុត្រឯអាយ ពុំដូចតាំងឡាយ
អស់កូនគេផង ៗ កើតមកជាឈើ ប្លែកសល់ឥតបើ
គុនគិតនេះម្ដង ឲ្យអាស្រូវកាស គួរខ្មាសក្ដាត់ហោង
មុខមន្ត្រីផង គេនឹងនិន្ទា ៗ ខ្ញុំដឹងសេចក្ដី
ដោយនាងក្សត្រី ប្រាំពីរអង្គ ខ្ញុំបានបន្ដេញ
ឲ្យចេញយាត្រា បោះបង់ឃ្លាតឃ្លា ពីថ្ងៃម្សិលបាត់ ៗ
ពីព្រះនរបតី ស្ដាប់បុត្រភ្ញាប្រឹ ក្សិណក្សត្រីរត
ស្ដេចទ្រង់ព្រះក្រោធ ពិរោធពេកក្ដាត់ នឹងព្រះរាជបុត្ត

ពុំចេញវាចា ៗ ស្ដេចពុំត្រអាល ដំណើរដំណាល
អំពីគុជសា គិតតែកូនពៅ ចេញទៅទីណា
ញាតិព្រះទិស្សា បន្ទូលថាហៃ ៗ ចំពោះនៅជា
ឥឡូវម្ដេចថា សម្រាលហើយនៃ យល់ជាអស្ចារ្យ
ពិកលចិត្តក្រៃ អញវៃង៍សង្ស័យ ប្រាំពីរស្ត្រី ៗ
បុរបូពណា សឹងពុំដែលមាន នៅលើផែនដី
កើតកូនជាឈើ ដូចពាក្យវាស្ដី ដៀមេអប្រិយ៍
ចិត្តកាចឫស្យា ៗ មុនមិញសឹងយល់ កាលវាផ្ញើកល
ទិស្សាបៀមបុផា កាច់កេ្ដិតតខ្ទះ ទិកាសមហិមា
ម៉ឺងនៅដឿវា ពុំរកហេតុផល ៗ ម្ដេចផ្ញើស្រែស្រាល
តាមដោយចិត្តពាល ខុសត្រូវពុំយល់ នាងបន្ទូលម្ចោះ
នេត្រាជោផល់ អាណាតិនមល់ ស្រីសុវណ្ណា ៗ
បន្ទោសទោះហើយ នាងពុំកន្ដើយ ទូលទៅកស្ដារ
សូមទ្រង់ប្រណី តាមរកបុត្រា នាងទៅឋានណា
សូមរកឲ្យយល់ ៗ ធម្មិកពជា ត្រាស់ប្រើសេនា
ឲ្យប្រាប់ពួកពល រៀបរាជ្ជយាន ក្សត្រក្សាន្ដច្រើនកុល់
ស្ដេចចាកមណ្ឌល ទៅរកធីតា ៗ កាលនោះសេណី
៤ ក្សត្រឃាតខ្ទី ចរចេញចាត់ការ ត្រែកត្រាស់បង្គាប់
ប្រញាប់ម៉ឺម៉ា តាមព្រះអាជ្ញា សូរេចហើយនៃ ៗ

ក្រាបទូលព្រះបាទ ព្រះបរមនាថ ឥសូរជៀសដៃ
ស្ដេចជ្រាបពុំលុង ព្រះអង្គយាងវៃ នូវនាងនាថថ្លៃ
ព្រះអគ្គមហេសី ៗ ឡើងគង់លើយាន ស្ដេចចរចេញឋាន
នូវអស់មន្ត្រី ក្សត្រ ៤ អង្គា នោះណាសឹងលី
លាហៃភូមី ទៅទល់អត្ថា ៗ កាលនោះពុំលុង
ក្សត្រ ៤ ព្រះអង្គ កំលៀងក្សត្រា ថ្វាត់ថ្វាយបង្គំ
ប្រណម្យលុតលា រត់រកជ័យ្យា ប្រសើរស្រស់ស្រី ៗ
ទោះទាំងសេនា ស្រពន់យាត្រា សាយសព្វទិសទី
សូរសព្ទនិក តូចធំផងក្ដី ឈ្ងុបឈ្ងោសរកស្រី
កែវសុវណ្ណា ៗ ក្បិនខ្ទះទៅយល់ បូផានិមល
ដែលព្រះទេស្សា នាំទូលក្សត្រ ៤ ថែថ្នួនពាចា
ស្ដេចយល់បូផា ស្គាល់ជៀងជាក់ក្រៃ ៗ ហើយស្ដេចតាមដាន
អរឯងគិតស្មាន នឹងយល់ស្រីថ្លៃ ឃើញផ្កាក្រុះពាយ
ក្លិនក្លាយប្រពៃ វៀងផ្លូវនោះនៃ រងំខំយាត្រា ៗ
លុះដើរដល់ស្ពាន គប់បុត្រកល្យាណ នៅនិគ្រោធា
ឃើញអស្ចារ្យក្រៃ ធ្លល់ក្នុងចិន្ដា ហិបអ្វីចេះណា
យល់ផ្លែកអស់ក្ដី ៗ ស្ដេចចរចូលឋាន ហើយទើបក្សត្រក្សាន
ឲ្យបើកហិបខ្ចី ទតយល់សំពត់ ទាំងផ្កត់ថ្មីៗ ៗ
លោហិតនោះក្ដី ជិតដោយកស្បា ៗ ស្ដេចថាទេម្ដេច

អំពើកល់កិច្ច ហេតុអ្វីប្បេះណា នេះសំគេស្អប់
ដីកកប់បុត្តក្ងា នាងបរយាត្រា មកបានយុងយល់ ៗ
ហើយនាងនាំបុត្ត ថ្ងៃថ្វាពិសុត ត្រេចត្រង់មណ្ឌល
សឹងហុនយក្សា បីតាទសពល មែនមិនគួរឆ្ងល់
ប្រាកដក្ដាត់ណា ៗ ហើយស្ដេចឲ្យយក ហិបវិលវឹងមក
ក្រាបទូលក្សត្រា នូវព្រះជិនី នាងស្រីសច្ចា
សូមព្រះភជា ផ្សាបព្រះហឫទ័យ ៗ ទ្រង់ព្រះករុណា
ត្រាស់លើសិរសា យើងខ្ញុំនេះនៃ ឲ្យរកជីតា
ពំណើរថ្ងើមថ្ងៃ រករសាយដៃ ពុំយល់ដេយក្សា ៗ
យល់តែមណ្ឌល បូផារៀងរល់ នឹងហិបនេះណា
សំព្រះផន្ទតោ សេរបោទគ្គឡា រូបរស់ជន្មា
មែនមិនក្រនៃក្ស ៗ ដោយពិភាក្សា មិនក្លូនទរណា
ឯទៀតដទៃ ស្ពានមកកាយគប់ ក្រោមម្លុបព្រះជ្រៃ
ចំប៉ាមាសមៃ ជ្រះជុំមណ្ឌល ៗ ប្បេះតើនរណា
នឹងមានបូផា ដូចនាងនិមល បើដោយគំនិត
គួរគិតកុំឆ្ងល់ សំដៅមណ្ឌល សឹងហុនភាព ៗ
តីរពង្សក្សត្រថ្ងៃ ពុសប្តិសុមៃ ក្សត្រ ៤ ទូលថា
ព្រួយព្រះហឫទ័យ អាឡ្យៃដីតា ហើយស្ដេចមីម្ញា
រួសរាន់ទៅផ្គន ៗ ផល់ដើមព្រះជ្រៃ ចុះចាកយានថ្ងៃ

ពុំលុះឡើយហោង ស្តេចទតទីបាន ដែលវាននោះផង
ព្រះទ័យវិងវង ទុក្ខទៀតខ្លោចផ្សា ៗ នឹកកូនឧត្តម
មាសបាកហោលចំ បែងបង់ឃ្លាតឃ្លា នាំទាំងជន្មគោ
វរៅថ្ងៃថ្ងា ព្រាត់ព្រះអយ្យកា អយ្យកោឯអាយ ៗ
ស្ងន្ធើយម្ដាយមេ មិនដឹងសោះទេ ជាមាសពន្រាយ
ប្រសូតិរាជបុត្រ ពិសុតឆោមឆាយ ខំខិងនឹងម្ដាយ
ជាពុំករុណា ៗ មួយកូនព្រលឹង ទោះប្ដីខេខឹង
ខុសគាប់កាបជា គួរនាំសាសព្ទ មកប្រាប់ម្ដាយរា
ម្ដាយនឹងដេជា សង្កត់អាយនាយ ៗ ម្ដេចឡើយនឹងអាល
ក្រោធក្រៃផល់ផាល លាកលះចេញឆ្ងាយ ឲ្យម្ដាយវិសាវង
ទ្រូងតឹងស្ទើធ្លាយ គិតហើយរិងស្ដាយ ស្ដាយពិតពុំក្លួប ៗ
កូនកែវកល្យាណ ម្ដេចមកក្បត់ហ៊ាន ក្រោធក្រៃផល់គិប
បោលម្ដាយសោះសូន្យ ណោកូនស្គួតសាប់ យាងយាត្រាត្រេច
ទៅបាទបីតា ៗ ម្ដាយគិតថប់ខ្វាច ក្រែងខ្លាចបីសាច
រាជកូតមាយា មានម្រេញគង្វាល កណ្ដាលអទ្វា
យល់ព្រះចៅជា កុមារក្ដាត់ហោង ៗ នឹងបៀតផ្ដួនា
ជន្មគោពុំងា កើតជម្ងឺផង ឥតមានអ្នកណា
វេក្យាស្ងូនត្រង់ មាសម្ដាយ ៗ វង់ ៗ ទុក្ខទោមនស្ស
ម្ដាយអាសូរសល់ ម្នាក់ឯងទុពល ពុំមានគ្នីគ្នា

ស្រណេះស្រណោច ត្រមោចកំព្រា សំសោយសោកា
សស្រាក់នេត្រនាង ៗ ឥស្សូនប្រសើរ យំសោកបណ្ដើរ
ហើយខំឃាសឃាង់ ទឹកភ្នែកហូរល្ហែង ស្រោចស្របសារពាង
ឆ្ងាយទីងឃ្វាង ខានយល់មុខមេ ៗ ទាំងព្រះបីតា
នឹងសោយសោកា ផោផល់ឥតល្ហែ សញ្ជឹងសញ្ជុប
ថែរថប់ធ្វេសធ្វេ ហេតុមានក្ដីស្នែ រាជបុត្រប្រុសា ៗ
កាលនោះពុលុង ក្សត្រ ៤ ព្រះអង្គ យល់ព្រះភជា
ទាំងពីរសោយសោក អាមោកក្ដាត់ណា ប្រណាម្យទូលថា
បពិតក្សត្រថ្លៃ ៗ សូមស្ដេបំហើយ កុំសោយសោកឡើយ
ព្រយព្រះហឫទ័យ ពុំលុងទឹងបាន វិលថ្កានមកនៃ
ប្រាកដពេកក្រៃ ពាក្យពុំមោសា ៗ ក្សត្រីបវរ
នាងនឹងចេញចរ ពាក់ពឹងអ្នកណា មានតែអាសុរិន
ភូមិទូបីតា ដូចពាក្យខ្ញុំថា មែនមិនឃ្លៀងឃ្លាត ៗ
ក្សត្រយកក្យាមល់ ស្ដេចស្ដែងទ្រង់ធម៌ ព្រះទ័យល្អក្កាត់
យើងទៅបង្គ ប្រណម្យក្រាបបាទ ព្រះបរមនាថ
ខត្តិវង្សយក្ស ៗ គង់តែព្រះអង្គ លះលែងបោះបង់
ពុំទ្រង់ក្រោធា សំបាននារី វិលមកសៃមា កុំស្ដេចសង្កា
គ្មានក្ដុំព្រះទ័យ ៗ ធម្មិកភជា នូវនាងសុជ្ជា
ស្ដេចស្ដាប់សូម៉ែ គ្រាន់ស្រាកគ្រាន់ស្រាន ស្រយ៉ាលព្រះទៃ

ទើបត្រាស់ថាហៃ ពួកពលសេនា ។ ហាបទឹងសំពត់
ឲ្យដាក់រាជរត ទៅទុករក្សា ក្រែងបានជួបជួន
កូនស្ងួនពំនាំ ទឹងពិភាក្សា ជំនុំឲ្យយល់ ។
ស្រេចទើបព្រះបាទ ធម្មិកនរាជ នូវនាងនិមល់
គង់យានប្រពៃ វិលវៃមណ្ឌល ដល់ស្រេចទសពល
ចូលក្នុងវាំងខ្មី ។ ស្តេចដល់ប្រាសាទ ប្រសើរស្អាងស្អាត
សោយសោកសែនធ្ងួ មមាមមៃ អាឡៃបុត្រី
ហើយគិតប្រណី ព្រះរាជន្ទតោ ។

## បទព្រហ្មគីត

កាលនោះព្រះបក្រិន បោមនរិនធិរាជា
ដៃដេតស្តេចគង់នា ប្រាងប្រាសាទប្រសើរក្រៃ ។
សោយសីលសាស្ត្រផង ព្រះបព្វាស់ប្បងត្រឹព្រះទៃ
ផ្អូកផ្អើសក្ខកអាឡៃ អាឡោះលន់ពេកពុំក្សាន ។
ត្រឹព្រួចអស់ឥន្ទ្រិយ គិតប្អូនស្រីថ្ងៃកល្យាណ
រំរិងទុបពុំបាន សែនសោយសោកក្រាបទិតនៅ ។
ស្រយុតស្ទុតអស់អង្គ ឡប់ឡៀនឡង់ខ្មោចផ្សាក្តៅ
ខេចិងខុសក្រែក្រៅ ក្រិតក្រមក្រែតក្សានថ្ងៃថ្ងា ។
បំបរប្អូនព្រលឹង ពុំរំពឹងពិចារណា

ឱប្អូន ៗ ពុំស៊ា មេបង់បង់បាត់ទីទៃ ៗ
ពុំដឹងមាសមេទៅ ទីលំនៅឋានណានៃ
ស្ដ្រើយបង់មមៃ មមាញឹករលឹកលន់ ៗ
មាសស្ងើយចិត្តបងឯង គិតរង្វេងក្រៃពេកពន់
បាបបង់បង់ប្អូនតន តនជាទ្រព្យហាបុទ័យ្យា ៗ
កាលនោះ ៤ អង្គក្សត្រ ចរចូលប៉ាត់វរវន្ទា
ថ្វាយផ្កាសុវណ្ណា ដែលព្រះឧស្សនាងនារី ៗ
ហើយទូលពីហិបដាក់ ដែលគេដាក់បុត្រភ្ញាប្រិ
សំពត់ទាំងផ្ទត់ថ្មី ផិតលោហិតនៅកស្យជា ៗ
ហើយទូលពីគេកប់ នាក្រោមម្លប់និគ្រោធ្នា
ស្ដេចជ្រាបក្នុងចិន្ដា ពីរាជបុត្រថ្ងៃត្រកាល ៗ
ឱសំពៅពំង៉ា នាំបុត្រាយាងកណ្ដាល
ព្រែព្រឹក្សទាំងអម្បាល ទៅសឹងហុនក្រុងបូរី ៗ
ឪពុកគិតស្មានថា កើតមកជាកូនអប្រិ
មែនពិតដូចសំដី មេប្រាំពីរទូលនេះណា ៗ
ស្ដេចគ្រោធក្រៃប្រាកដ ហើយរំអត់ក្នុងចិន្ដា
គិតកេ្ដ៍គេនិន្ទា ឥតបំណោះបាញ់កលស្រី ៗ
ស្ដេចខ្វាល់គង់គ្លួនគុំ ស្ងៀមសម្ងំសត្វរាទី
ប៉ងផ្ដេចផ្ដន្ធជីវី មេប្រាំពីរអង្គនោះណា ៗ

វន្តអស់ឥន្ទ្រ　ស្ដាប់សំដី៤ក្សត្រា
ទទួលយកបំពង់　រិនថែបប់ទុកទៀតខ្វី ។
ស្ដេចជាតុបំពង់　សុវណ្ណជាសាក្សី
តីមាត់មាសប្រិមប្រិយ　ឲ្យបង់យល់សោះស្រណោះ ។
ទុបង់ធំក្នុងពៅ　ជាប់បាំនៅរឹងតាឡោះ
ស្រយុតអស់ពង់ពោះ　ពិតពុំមានស្រោនទុក្ខា ។

## បទកាក

យើងនូវស្រដី　ឯវក្សត្រី　នឹងរាជបុត្រា
គង់ព្រះរាជរថ　រន្ធតលេលា　កាលនោះឥន្ទ្រា
បំប្រញផ្លូវផង ។　ផ្លូវឆ្ងាយទៀងទេ　កំណត់មួយខែ
ទើបដល់ផ្លូវបង់　ត្រើបតែមួយថ្ងៃ　ធាប់ក្រែកនូវ
ដល់ស្រុកមួយហោង　ជិតបុរីសេមា ។　កាលនោះព្រះឥន្ទ្រ
ពោមហៅនរិន　ឥសូរស្នូគិ　ចូលចុតឆ្នេរស្រះ
ឲ្យព្រះពុទ្ធិតា　ចុះបាតរត្នា　សំដៅស្រះស្រង់ ។
នាងចុះទៅផ្គង់　ទឹករង់ថ្ងៃយុង　ផ្គតបុត្រស្នូនត្រើង
ថ្មមចើបសិរសី　ស្រដីស្នេស្នង　កូនទើយនេះម្តង
ជិតក្រុងភាព ។　ហៃកូនឥតសៅ　ស្នូនទើយបាបៅ
ឲ្យផ្តតហោងណា　ថ្ងៃល្ងាចស្រយាល　នឹងកាលយាត្រា ។

ថ្កានអយុកាព  បុត្របណ្ដូលថ្ងៃ ៗ  ក្បិននាងបំភ្លៅ
បុត្រតេចាមចៅ  សូរេចហើយនៃ  ឡើងលើកដរត
សង្វាតឆាប់ក្រែ  បរបានដល់ញ្ញ  ក្ដីពងសៃមា ៗ
ឯអស់យក្សយុង  យល់នាងវិវង្ស  អអឹងគ្រប់គ្នា
រួតរត់ទទួល  ស្រើបស្រួលវន្នា  ហើយហែរដេយ្យា
ដល់ប្រាសាទហាន ៗ  ស្នំស្និតទាសា  យល់នាងធីតា
ភិតភៃគ្រប់ប្រាន  ប្រការកល់ម្ដេច  នាងត្រេចមកប្ដាន
ឯកឯងពុំមាន  សេណីសេនា ៗ  ចូលមកបង្គំ
ស្រីរតនុត្ដម  ទូញទូលថ្ងៃងថា  ហេតុម្ដេចព្រះអង្គ
ត្រេចត្រង់យាត្រា  តែឯកអង្គា  ប្រការកល់អ្វី ៗ
ព្រះវៀមកជា  ស្ដេចគង់ឯណា  ឃើញតែក្សត្រី
នាងស្ដាប់កាថា  ទាសាទាសី  អៀនពុំស្រដី
តបទៅឡើយណា ៗ  តរបុត្រកល្យាណ  លីលាឡើងប្ដាន
ប្រាសាទសោភា  ក្រញូំក្រាបះក្រាមបាទ  ភូវនាថបីតា
សែនសោយសោកា  កាលនោះភាសុរី ៗ  ស្ដេចចុមប្រាំ
ឱបបុត្រពំនារ  ប្រសើរស្រស់ស្រី  នូវព្រះជនតា
សេដ្ឋាធិបតី  ស្ងួនគ្រង់បេតី  សួរសោកម្មីម្នា ៗ
ហៃស្ងួនស្ងួតសាប់  ប្រការកល់ម្ដេច  មេមកឯកា
សំមានហេតុអ្វី  កូនស្រីព្រាប់ក  ឆាប់ ៗ បីតា

នេះនឹងបង់ជីវ ៗ នាងសុវណ្ណា ទូលទាំងសោកា
អួលអាក់ដញ្ជឹង ព្រះទ័យបង់លាក់ ស្តេចយក្ខក្សត្រិវង
ចិតចំផណ្តឹង ខ្ជាន់ ៗ ជាម្តង ៗ ហើយវរក្សត្រី
ទូលក្រុងអាសុរី ពីដើមទំនង ទូលកាលព្រះបាទ
ទនាបប្រាស់ប្រង ស្តេចលីលាផ្គង ទៅទាក់គុជ្ជសា ៗ
ទូលពីខ្លួននាង នូវក្រោយស្តេចយាង ប្រសូតិបុត្រា
ហើយនាងសុរីល ប្រាំពីរអគ្គា ធ្លាក់ឈើធ្វើជា
កូនកាលនោះហោង ៗ ទូលកាលយកបុត្រ ថ្ងៃថ្កាពិសុត
ទៅកប់ទៀតផង ទូលកាលក្សត្រក្សាន វិលថ្កានមកផ្គង
នាងទាំងនោះហោង ក្រាបទូលក្សត្រា ៗ ទូលកាលព្រះអង្គ
ខ្វាល់បំបរបង់ ដោយពាក្យគេថា ទូលកាលនាងស្តេច
ត្រេចចរយាត្រា ទូលកាលវិទ្យា ដឹងដើមបុត្រថ្ងៃ ៗ
អង្គឹសំកូន ក្សិនក្ស័យសោះសូន្យ កណ្តាលព្រឹក្សព្រៃ
គុណនាងវិទ្យា នេះណាធ្ងន់ក្រៃ នាំខ្ញុំទៅវៃ
យកបុត្រពុំឆា ៗ ខ្ញុំបានបុត្រស្រេច ខ្ញុំយាត្រាត្រេច
ថ្កានព្រះបិតា ហេតុបុណ្យសំភា កុមារថ្ងៃថ្កា
ព្រះឥន្ទ្រកាឡា ពាជរត់មកថ្វាយ ៗ ខ្ញុំឡើងលើរត់
បរបានកំណត់ ថ្ងៃមួយដល់អាយ សូមប្រោបទេយ្យា
ក្សត្រាពន្រាយ កើតហេតុនូវនាយ ដ្បិតគេបុស្សា ៗ

# បទពំនោល

កាលនោះអាសុរិនពជា ជ្រាបដូច្នោះណា
ស្តេចខ្វាល់ពន្ទឹកពេកក្រៃ ៗ ហាក់ក្តៅឆេះឡើងវិសៃ
ពុងពោះហឫទ័យ រន្ធត់ទាំងព្រះអង្គា ៗ
នេត្រប្រាលបីរន្ទាលក្តា សេញស្វាញទន្តា
សំបុសំបើមកំរោត ៗ ក្រោធក្រៃក្សត្រថ្វីប្រឡោត
ស្វាញស្អុះលោលោត កំរើកទន្ទ្រំបាទា ៗ
ហាក់ផ្កាប់បីត្រឡប់កស្រធា អស់អង្គយក្សា
រដើបរដួលគិតក្រៃ ៗ បើកបន្ទូលទៅថាហៃ
កូនស្ងួនមាសថ្លៃ សំលួតសំឡាញ់បីតា ៗ
កុំមេថប់ថៃសោកា មេមើលកាលគ្រា
ឥឡូវឲ្យយល់ស្តែងជាក់ ៗ ធម្មតាក្សត្រាសិទ្ធិស័ក្តិ
ថ្កើនថ្កានប្រតិយក្ស សំបូណ៌សំបត្តិសក្តិតា ៗ
ដែលពោលពាក្យពុំសត្តិយា កកូតបរា
កហិកកុហកពុំត្រូវ ៗ ទោះខិងខុសគាប់ម្តេចកូវ
គួរគិតឲ្យត្រូវ បរំបូរណក្សត្រា ៗ
ម្តេចឡើយផល់ក្រេវក្រោធា ពុំយល់យើងជា
ឥពុកផល់ប៉ុនធុលី ៗ គួរខ្មាស់អស់ពស្តមន្ត្រី

ស៊ីវក្សដីវី
ប្រាកដកណ្ដាលវៀនរុង ៗ
ក្សិណស្ដេចឲ្យហៅយក្ខយុង
សេនាបួនអង្គ
ដំទិតដំនៀស័ក្ដិសិទ្ធិ ៗ
ក្រៀវក្លាហៅហ៊ានបីពន្ទឹក
មិនមានក្បកក្បឹក
នូវសិកសត្រូវនានា ៗ
ស្រវឹងបីរបឹងសោះសា
ឈ្នះសឹកច្រើនគ្រា
ហ៊ានក្លាម្នោម្នះនឹកភ័យ ៗ
ធាត់ធំដូចក្នស្កុមស្ក
សិងហុនចូដៃ
បំបាក់បំបបសតូហាន ៗ
ក្សិណោះក្សត្រយក្ខប្រធាន
ស្ដេចត្រាស់ទៅថ្កាន
ទាំង ៤ មន្ត្រីយក្ខយុង ៗ
ហៃយក្ខសិទ្ធិសក្ដិទ្រនុង
ចូលធាប់កំលុង
ប្រាមប្រាប់អស់ពលយក្ស ៗ
ទៅចាប់ហេមន្តភាព
ផ្កាញឲ្យមរនា
វិនាសកុំឲ្យរស់បាន ៗ
ទាំងរាស្ដ្រទាំងក្សត្រដប្រធាន
ភូវកុំឲ្យមាន
សេសសល់សំណល់ឡើយណា
ចាប់ទាំងដៃដេតបុត្រា
នូវនាងសច្ចា
សម្ដេចព្រះវរជិនី ៗ
ចាប់ទាំងធម្មិកភូមី
កុំមានប្រណី
ពិឃាដសម្លាប់ជន្មា ៗ
ក្សិណោះទាំង ៤ សេនា
ស្ដាប់ក្រុងយក្សា
មានព្រះបន្ទូលប្រើប្រាណ ៗ
ប្រណម្យទ្រាស់ឆ្លើយទូលថ្កាន
បពិតសូម្នាន
យើងខ្ញុំទឹងយកអាសា ៗ

កុំព្រួយកូនព្រះទេយ្យា ខ្ញុំនេះធានា
ចេញទៅកំទេចព្រះបង់ ។ មនុស្សម្នាប្រជាពលពន់
សេនានៅអន្ត ឥស្សូរសម្បត្តិពជា ។
អត្ថិភាព ពលឯកយក្សា អ្នកអានវិទ្ធា
ក្រាបទូលសម្តេចចក្រី ។ ខ្ញុំហោះផ្លេកផ្លោះនុក្តី
ឯកអង្គកំបី ប្រាបមកនៅរកវេហ៍ពល ។
ខ្ញុំផាន់ហោមន្តមណ្ឌល ផ្សៀងផ្ញើលរបល
រំដើបរំជួលកិតកៃ ។ លុនលិចបាត់បង់ហ៊ានហៃ
ស្តុតស្ទាប់ក្បិនកៃ្យ សូន្យសោះទៅក្នុងសាគរ ។
សត្វផងពិទូនផ្ទាមមក ទឹងមានអំណរ
បរិភោគបំរែតឥន្ទ្រី ។ រុលមេឃយក្ខយន៍អាសុរី
ទូលព្រះនរបតី នរិនទនរេនភជា ។
ខ្ញុំទឹងយកដៃប្រ៉ា ការកើបមនុស្សម្នា
ពុំឲ្យសេសសល់មួយឡើយ ។ ផ្សិក្រាយក្បាឥតត្រើយ
នូវឯងថ្នាស់ផ្ញើយ សម្បាសម្បើមរិទ្ធីកៃ
បពិតហោមន្តនោះនៃ យល់ពុំស្មើដៃ
ពិជ័យសង្គ្រាមបីនូវគ្នា ។ ខ្ញុំហោះផ្លេកផ្លោះវេហាស៍
ស្មុសស្មយភាព មកថ្វាយសម្តេចនរបតី

តាមតែម្ចាស់សិរសី ភ្ញើកលម្ដេចក្ដី
ខ្ញុំខ្វិលនឹងតតេជៈដៃ ៗ យល់ថយយល់ថោករិទ្ធិជ័យ
តិចទឹងចិត្តក្រៃ ពុំគួរជាគួរឿនរុង ៗ
ដូចកលមមាចនៅមុង ជួរជាតិចិត្តចង់
រំលុតរំលាយអាគី ៗ អាយុកាលយក្ខយង់ជរិទ្ធី
ទូលថាកុំប័ ព្រួយចិត្តនឹងនឿយយាត្រា ៗ
ខ្ញុំក្រោកឈរឈោងហត្ថា ពីកាយនេះណា
ឲ្យដល់ហេមន្តនាយនោះ ៗ ប្រាំគៀតប្រហោស
ឲ្យវិនាសអស់ ប្រឡៃប្រលុងមរនា ៗ
ហើយកើបទាំងផែនកស្រា ហោកហោះក្នុងមហា
សាគរនៃគម្ភីរ ៗ

## បទកាក

ឯនាងនាងថ្ងៃ យល់យក្ខក្រោធក្រៃ គន្ធនគ្រប់គ្នា
នាងគិតតែខ្លាច អំណាចបេស្ដា ញាក់អស់អង្គា
អៀនទុនសិរសី ៗ នាងលើកទសក ទួញទូលអង្វរ
ពោមពៅអាសុរី សូមទានព្រះបាទ ននាថធិបតី
សូមស្ដេចប្រណី កូនកែវកំព្រា ៗ បំណោរពៅលង់
កូវកូនទីងចង់ កើតគេនិន្ទា ដំនៀលអស់ពស្ត្រ

ទាំងផ្ដាស់ទឹងថា ស្រីស្រើបពុំជា ហ៊ានសម្លាប់ប្ដី ។
មួយសូមប្រោសប្រាណ ជនតោកល្យាណ ទុរសពិសី
ពុំយល់ឪពុក កើតទុក្ខទៀតខ្ចី សូមស្ដេចប្រណី
អត់ទោសទៅហោង ៗ ទោះទឹងសម្លាប់ លុះនៅកណ្ដាប់
ព្រះហស្ថជាម្ដង តែថាសូមព្រះ លាកលះក្រោធផង
អាសូរស្ងួនគ្រង កូនតូចនេះណា ៗ ទាំងនេះកម្មខ្ញុំ
ឯងអាចឲ្យបំ បែងបង់ឃ្លាតឃ្លា ជាតិមុនមិញធ្វើ
អំពើពុំជា ជាតិនេះវេរា ដូចដល់នេះម្ដង ៗ
ប្រដូចស្រមោល តែងតាមអន្ទោល ពុំរួចរំលង
ហេតុនោះកុំគិត បង់ចិត្តបស្នង តាមដោយគន្លង
ព្រះពុទ្ធសាសនា ៗ ឯក្រុងអាសុរី ស្ដេចស្ដាប់បុត្រ
ទួញទូលបរោរ ក្សត្រយក្ខថ្កើងថ្កាន ទ្រង់ធមិក្ដាត់ណា
អាសូរធិតា ស្រាកស្រាន្តព្រះទ័យ ៗ ប្រណីកុមារ
ជនតោត្រកាល បុណ្យបារមីក្រៃ ស្ដេចថ្នមត្រកង
សាសងថាហៃ កូនន្ទើយម្ដេចនៃ ឯងគិតប្នេះណា ៗ
ឪពុកគិតទៅ អាសូតែចៅ កុមារមហិមា ឃើញតែមុខម្ដាយ
ឃ្លាតឆ្ងាយបិតា រឹងជាកំព្រា ត្រមោចនេះម្ដង ៗ
លោកដែលជាក្សត្រ មិនមានពាក្យសត្យ បញ្ឆោតលេងលង់
គាត់ស្ថានមេត្រី ឥតបីសាសង ប្រាយប្រាប់យើងផង

អាលក្រេវក្រោធា ៗ នាងទូលទៀតទៅ បពិត្រព្រះបៅ
សូមទ្រង់ករុណា ស្ដេចនឹងគិតឯង ពុំក្រែងចិន្ដា
មិនច្នោះមាទរ៉ ប៉ុំពីរនោះនៃ ៗ គេទូលញុះញង់
ឲ្យព្រះអង្គទ្រង់ ក្រោធក្រៃសែនធ្ងី អគ្គីខ្វាល់ឯង
ពុំឈ្វេងសេចក្ដី ទាំងនេះពៀរពី បរមជាតា ៗ
ក្សត្រយក្ខប្រធាន ស្ដាប់បុត្រកល្យាណ ទូលទើបក្សត្រា
បើកបន្ទូលឆ្លើយ កូនអើយកុំជា ទុក្ខសោយសោកា
ចប់ថៃឡើយហោង ៗ ឪពុកថៃទឹង មិនឲ្យព្រលឹង
កើតក្ដីសៅហ្មង លុះអស់ជីវិត ឯងឥតឲ្យឆ្គង
អាសូក្ដាត់ហោង ស្នេហបុទ័យា ៗ ហើយព្រះភូណៃ
លើកឱរសថ្វៃ ដាក់ដល់ឪរ៉ ថ្នមថើបព្រះភក្ត្រ
នៃអ្នកពុំងា ឱស្ទនជីតា ល្អម្ដេចដល់ម្ទេះ ៗ
ត្រកាលនឹងបុណ្យ ឥតអ្នកនៅប៉ុន មានមកដូច្នេះ
កបន្ទូវទេរ កាឡាវទេះ ហើយមានទាំងសេះ
ជួយជូនមកណា ៗ មានទាំងគ្រឿងទ្រង់ ប្រដាប់ព្រះអង្គ
ល្អល្អះសោភា ទាំងម្កុដព្រះខាន់ កៅទាន់សរថ្វា
ត្រកាលជាតិជា អស្ចារ្យក្ដាត់ហោង ៗ ហៃព្រះជនគោ
អញឮយុគោ អរក្រៃកន្ទង បាបានមកដល់
យុនយល់ដូចប៉ង អគ្គីនេះម្ដង សំក្សេដន្ទា ៗ

ឪស្ងួនកំសត់ តាចិនចំអត់ អាសូតែបា
ដោយចិត្តអំពើ សំរេចពីតា បាមិញមរនា
បង់បាត់ជីវី ៗ នេះម្តងតាគិត រិសរិងអាណិត
អ្នកមាសក្លាប្រី ពុំដឹងបើកាត់ ស្លាប់សត្វមេត្រី
អល់ឯកប្រណី លះលែងក្រោធា ៗ ពុំយូរលុងក្តាត់
ជិនុកបាថ្វាត់ មកថ្វាយវន្ទា នឹងបានជួបជួន
កូនស្ងួនសង្សារ មូលមួយនឹងគ្នា មិនលែងឡើយហោង ៗ
កាលនោះព្រះបាទ អយ្យកោនាថ ឲ្យមន្ត្រីផង
រើសរកមេទុំ ទាំងស្រីស្នំផង រើសរូបឥតគ្គង
ទ្រង់ឆោមឆាយា ៗ រើសទាំងត្រកូល ពូជពង្សអំបូ
ក្សត្រកាន្តថ្ងៃថ្វា ខ្លួនតូចសខៀវ រាងរៀវសោភា
ល្វាសល្វន់កាយា ព្រះកន្ត្របប្រែ ៗ យកតែដោះក្សំ
បីបំបៅសំ នឹងព្រះឱស្ឋថ្ងៃ ខ្លួនពុំសូវសារ
យល់ល្អប្រពៃ ទឹកដោះពុំប្រែ ល្ហក់ល្ហមពិសា ៗ
ទោះបីប្រែនាក់ ខ្សែត្បាញមានលាក់ នោះសោតសឹងជា
យកមកបំបៅ ព្រះចៅកុមារ ទឹកដោះពិសា
ផ្អែមក្រៃកន្លង ៗ សន្តាយរយាក យូរយាស្រប៉ាក
ពុំឈ្លៀងជាម្តង ដោះខ្វាក់ដោះញ៉ាំ មិនល្អឡើយហោង
ពុំសំគួរផង ព្រះរាជនតោ ៗ រើសទាំងកំលៀង

បំពេរជ្រួបជ្រៀង　សម្រាប់ព្រះពោ　ធិសត្វវរវង្ស

ទដុង្គុទត្តមោ ស្តេចជាអនុត្តា សាសត្ថសំខេយ្យា ៗ ហើយយក្ខយុនថ្ងៃ

ឲ្យរៀបចំដៃ　រាជបុត្រពុំងា　នូវរាជទិរស់

ព្រាណប្រុសថ្ងៃថ្វា　មុខមន្ត្រីត្រា　គង់គាល់រៀងរាយ ៗ

ប្រដាប់គ្រាន់គ្រប់　មើលមានម្ហាស្រេព　ក្មេងក្ជាត់ទាំងឡាយ

កក្រើកក្ខាយខ្ច　ខ្វាខ្វព្ញាយ　អឹងអាប់សព្វសាយ

ព្រុំពីរទេវ ៗ　ហើយថ្វាយនាមករ　បុត្ររតន៍បវរ

ស្តេចឲ្យហៅជា　ទ្រាយធិបេ៉ស　វិសេសសោភា

ព្រាមព្រឹធហោព　អរឲ្យព្រះពរ ៗ　ហើយថ្វាយកិលៀង

ទាំង ៤ ទទៀង　សឹងក្សត្របវរ　ឲ្យតែងពិភាក់

រៀមពក់គូច　ស្នេស្និតស្មោះសរ　ពិតពុំសង្កា ៗ

អង្គមួយប្រាកដ　នាមនៃសន្ធតិ　ពិចិត្ររចនា

ល្អល្អះបំណាប់　គួរគាប់សោភា　មួយឲ្យនាម្ចា

វត្តចិត្តប្រុះប្រួង ៗ　មួយទៀតឯកអង្គ　វង្ធបេសសូវង្ស

បន្ទាប់នោះហោង　ឈ្មោះនេតកុមារ　ពិសាលសួនគ្រង

ពុំដែលឲ្យគ្គង　ព្រះរាជបិន្ទា ៗ　បរិពារនារី

ស្នំស្និតទាសី　ណាស់ណាន់តៀបត្រា　ខ្ទះកាំខ្ទះប្រៀង

សំនៀងបរចារ　បន្ទូងព្រះមហា　បុរសរត្នថ្ងៃ ៗ

ស្ងួរស័ព្ទរងុំ　ពិរោះរណ្តំ　ក្រលួចព្រៃក្រ

ស្រងាត់ល្វេងល្វើយ ល្ហឹមល្ហើយវិសែ ស្រីសួគ៌ាលៃ
ប្រៀនប្រូបពានា ៗ ខ្វះបង់អង្រឹង បបកប្រលឹង
អញ្ជើញនិន្ទ្រា យោលហើយបំពេ កាយកៃហាត្ថ
ផ្ទៀងផ្គងកាន់គ្នា សរសើរបារមី ៗ ខ្វះបំពេថា
អ្នកមាសពំងា ត្រកូលជាតិ មាសសើយសម្រាន
ក្សេមក្សាន្តសួស្តី ស្កប់ហើយឡើងខ្ញី ស្រាប់ស្រងគន្ធា ៗ
គន់ទៅទឹកអប់ ឈ្ងុយឈ្ងុបត្រឡប់ សឹងគ្រឿងគន្ធា
ក្របេះបូងចន្ទ សោកាន់ថ្ងៃថ្វា អាងមាសមាលា
វាស់ដាំមុនី ៗ ស្រង់ស្រោចក្រសាល នូវអស់អម្បាល
ខ្ញុំប្រុសខ្ញុំស្រី ខ្វះតូចខ្វះធំ ខ្វះពុំបារី
ខ្វះទើបបួលថ្មី ពាលពេញក្រមុំ ៗ ខ្វះបីខ្វះថែ
ខ្វះលួងខ្វះព មិនឲ្យមានយុំ សំបូណ៌សម្បត្តិ
ស្ទួតប្ចត្រត្រសុំ ម្ចាស់សើយកុំយុំ សូមទ្រង់មេត្តា ៗ
មាសសើយស្រុកយើង រុងរឿងថ្កុលថ្កើង យឹនយសសក្តិតា
នគរជងៃ ចាញ់ដៃរុញរា មូលមកវន្ទា
ថ្វាយសួយអាករ ៗ ប្រទេសនានា ខ្វបខ្វាបបេស្តា
សម្តេចកូជរ ទ្រើសទ្រង់ពជរុំ បរមនគរ សាយសុខសាទរ
ល្បីល្បាញរុងរឿង ៗ ព្រះកេរព្រះយស ចរៃញ្ចូងខ្ពង់ខ្ពស់
បុណ្យបារមីថ្កើង សត្រូវខ្វបខ្វាប អំណាចម្ចាស់យើង

| | | |
|---|---|---|
| តាមតែចំនើង | បំណាំងចិន្តា ៗ | វៃនិពាទ |
| នេះនឹងបង្ខាន | ស្ទុះពុំបរបារ | យើងទូវបាយបែង |
| ថ្វាថ្វៃងពានា | ហេមន្តភាព | រដ្ឋពជជានី ៗ |
| ដៃដេតកជា | ស្តេចសោយសោក្កា | គិតព្រះមហេសី |
| ស្តេចពុំស្រស្រិទ | ផ្តេកផ្តិតមេត្រី | នឹងអស់ចាំងស្រី |
| ប្រាំពីរនោះណា ៗ | រឹងគិតរឹងខ្វល់ | ពិតពុំស្រយាល |
| ក្នុងព្រះចិន្តា | សង្រេងស្រួលស្ងប់ | សញ្ចប់កន្ត្រា |
| កាលណោះធិតា | ប្រាំពីរមហេសី ៗ | នាងយល់ព្រះបង |
| សោយសោកវីងវង | ទុក្ខសោកសែនធ្វី | នាងថ្វាយបង្គំ |
| ប្រណម្យស្វាមី | បពិត្រហេតុអ្វី | ស្តេចទ្រង់សោក្កា ៗ |
| ក្រែងយើងខ្ញុំផង | គាបឲ្យគ្គាំគ្គង | ទឹងព្រះចិន្តា |
| ឬមានបើខ្វល់ | ពិគាល់ត្រង់ណា | ឬមួយរោគ្គា |
| បៀតបៀនព្រះអង្គ ៗ | ស្តេចស្តាប់ទំនូល | នៃនាងនាងទូល |
| ក្សត្រក្សាន្តវរវង្ស | ពុំបើកព្រះសូរ | បន្ទូលត្រេកត្រង់ |
| រឹងទូលលោមលង់ | ស្តេចពុំបរបារ ៗ | ឯអស់ក្សត្រី |
| យល់ព្រះបក្រី | ស្តេចពុំនាំពា | រឹងផ្អើញុកញក់ |
| និចងក់មាយា | លួងលោមពជា | ផ្តេកផ្តិតមេត្រី ៗ |
| ស្តេចពុំបេតនា | អៀនអន់ចិន្តា | ស្ងៀមស្ងាត់សំដី |
| ក្រៀមក្រំស្រមេះ | ពង្វិសអប្រិ | ថុចថប់ថយខ្វី |

ជជែកជុំគ្នា ៗ ខ្លះថាអញយល់ សំព្រះទសពល
ជ្រាបព្រះទ័យក្សា ស្ដាយពុំសម្លាប់ ឲ្យស្លាប់កាលគ្រា
នោះមិញសិនជា កុំទុកឲ្យនៅ ៗ នេះមន្តគិតខុះ
ការនេះនឹងចូស់ ដ្បិតគិតពុំត្រូវ បង់កេរ្តិ៍បង់ការ
អាសាអាស្រូវ ដំនៀលគេគូរ មានមិនឃ្លាតឃ្លា ៗ
កាលក្រោយអាចៅ ព្រះបាទចោមចៅ ប្លែកនឹងសត្វគ្រា
ពុំដែលនៅបាន រួមស្ថានស្នេហា សំព្រះពជា
ជ្រាបអស់កិច្ចកល់ ៗ ឲអ្នកឯណា នាំសុវណ្ណា
អាចឲ្យទៅយល់ កូនកប់កណ្ដាល អគ្គាទុរពល
អញគិតអញឆ្ងល់ ដឹងដោយនរណា ៗ ខ្លះមានយោបល់
ឆ្លើយថាអញយល់ គឺមេវិទ្យា មិនអ្នកដទៃ
ក្រៅក្រែកនានា ដ្បិតកាលនោះវា ពួនពុំឲ្យយល់ ៗ
ក្នុងព្រៃស្ងាត់ វាចេញបាត់ តាមមើលកិច្ចកល
មិនគឺនរណា យាត្រាទៅយល់ ដ្បិតយប់សូនសល់
គេដេកគ្រប់គ្នា ៗ ឲពីនេះនឹង កើតក្ដីកុំដឹង
ក្រៃក្រមហិមា ដឹងដល់យក្ខយុង សោកទ្រង់ក្រោធា
មួយព្រះមាតា បិតាឯនាយ ៗ ពានពឹងសំអប់
រិងប្រួតប្រទុប ទោសទុក្ខសម្ពាយ ឲគិតទៅគ្រប់
រីងថប់អំបាយ ទ្រូងទ្រូតស្ញើផ្កាយ គានគឹងពេកពន់ ៗ

សង្វាតផ្សងយស  បែជាក្លាយចាស់  ថោកថយសក្ដិបុណ្យ
វិបាកកាយកម្ម  ប្រចាំលើសលន់  ឲ្យរងទុក្ខធ្ងន់
ពិតពុំស្រាកស្រាន្ត ៗ  ឱយើងនេះម្ដង  ខាតខុសបំណង
ប្រាជ្ញាពុំបាន  តែងគោងគំនិត  គុនគិតយល់ខាន
ខុះខូចទាំងប្រាណ  ប្រាំពីរអគ្គា ៗ  នាងគិតស្ងុកស្ងក់
មុខមិញអាក្រក់  ក្អែកសរសោះសា  សន្ធៃសន្ធឹក
ស្ពោតស្ពិកទុរា  ស្ងប់ស្ងួតក្រ្ដា  ស្រពោនពេកក្រៃ ៗ
ឯអគ្គព្រះបាទ  សោយសោកនាងនាថ  នូវពរបុត្រនៃ
ថាទិះទុស្ងួន  ខ្ញិមខ្លួនថ្លើមថ្លៃ  ក្រែងតែបងខ្វែ
នោះទើបបងខាន ៗ  បើជីវិតរស់
បងនឹងតាមពោះ  ទៅរកកល្យាណា  ទោះក្សត្រយក្សា
គ្រោះធាហៅហាន  ពុំអត់ទោសប្រាន  ដល់ទៅប្រហា ៗ
បងមិនស្ដាយខ្លួន  ស្ដាយតែប្អូនស្ងួន  នឹងបុត្រពំនារ
ទោះបីបងក្សែ  ប្រឡៃជន្ទា  ខ្មោចបងនេះណា
ផ្ញើលើប្អូនហោង ៗ  ហើយព្រះភូមី  ប្រាប់អស់មន្ត្រី
ឲ្យរៀបពលផង  ស្ដេចនឹងលេលា  យាត្រាដោយដង
តាមព្រះប្អូនហោង  នឹងបុត្រពុំនារ ៗ  មន្ត្រីទាំងឡាយ
ប្រុងប្រៀបខ្វល់ខ្វាយ  តែងតាមអាជ្ញា  ហើយឡើងក្រាបទូល
ឥសូសិរសា  ទើបស្ដេចទៅលា  ទាំងពីរក្សត្រក្សាន្ត ៗ

ព្រះវរបិតា នូវនាងសច្ចា ទេវីប្រធាន
ឥនអគ្គិសិរសា វន្ទាក្សត្រក្សត្ត ទូលថាសូមទាន
ជ្រាបព្រះទ័យា ៗ ខ្ញុំបុត្រវរលក្ខណ៍ សូមក្រាបលាអ្នក
ចេញចាកសេមា នឹងតាមស្រីបំ ប៉ាថោងថ្ងៃថ្ងា
នឹងឥរស្យា ឯសឹងហុននាយ ៗ មួយបើបានយល់
មុខមាសនិមល ថ្មើមថ្ងៃពន្រាយ យល់ជាកូនប្រុស
រួបរស់រូបកាយ វិលវឹងថ្ងាត់ថ្ងាយ បង្គំវន្ទា ៗ
ប្រសិនខុសខាត ទៅហើយពុំបាន យុងយល់កក្ត្រា
កុំស្ដេចទន្ទឹង ទូលបង្គំណា តាមទៅលុះត្រា
ជួបជួនជួបប៉ន់ ៗ ទោះក្សត្រយក្ខយុង ក្រោធក្រៃពុំទ្រង់
ករុណាឡើយហោង តាមបុណ្យអាត្មា កាលគ្រានេះម្ដង
កូនទទួលរង ទោសតាមវេរា ៗ ពីព្រះបក្រិ
ស្ដាប់បុត្រពីសី ទូលទើបក្សត្រា បើកបន្ទូលថ្កាន
សងសានត្រាស់ថា កូនអើយបើបា តាមទៅគាប់ក្រៃ ៗ
អាណិតនាងណា នូវបុត្រសង្សា ចាកចេញទីទៃ
យើងតែងតានតឹង វិសរឹងអាឡៃ ឥអាសូក្រៃ
ធ្លាប់យល់កក្ត្រា ៗ មួយបើបាទៅ ចូលដល់លំនៅ
អាសុរិនពជា ទោះស្ដេចយក្ខខ្ញាល់ អម្បាលដេជា
ម្ដេចៗកុំបា ប្រទុស្ដធ្វើយស្នង ៗ បូរខំអត់ឥន

ប្រាណប្រែបលំទោន កុំបាឲ្យគ្គង់ ព្រះទ័យយក្សា
ខ្ញាំងខ្លាក្តាត់ហោង អង្វរសាសង ឲ្យស្រួលចិន្តា ។
រិភជបុត្ររតន៍ ទិនអង្គប្រតិបត៍ន៍ ទទួលវាចា
កាន់គួបចង់ប៉ាំ បណ្តាំបិតា បង្គំលុតលា
ចេញចាកពរគ្គង ។ ឡើងគង់គុជ្ឈសា ពលពាលគ្រៀបគ្រា
វៃហព្រះប្យះប្យង ទាហានសេនា យោធាឝឹងកង
សូរសព្ទរំពង បង្អៀតមាគ៌ា ។ កិលៀងទាំង ៤
វៃងរក្សាសួន ពុំឲ្យឃ្លាតឃ្លា តាមហៃព្រះបាទ
ននាចថ្ងៃថ្ងា ស្តេចដល់អដ្ឋា ព្រៃព្រឹក្សទួលទី ។

(ខ្សែ ៥ សង្ខេបតែប៉ុណ្ណេះ)

ខ្សែ ៦ ដើម ស្តេចជ័យជេតវង្វេងផ្លូវអស់រយៈ ៣ ឆ្នាំ

កណ្តាល ទ្រាយធិប៉េសកុមារត្រូស្តេចដៃជេត

ថាស្តេចជាបិតានឹកខ្វល់ខ្វាំងណាស់ទើបបាញ់ស្តេចទឹងផ្លូវ

បុង នាងចំប៉ាជោងទឹងស្តេចជ័យជេតសោក

សង្រែងកល់វេលាដោយជួបហើយៗពុំបានរួមមេត្រី

# សៀវភៅដែលផ្សាយចេញពីគេហស្ថាន គីម-គី

| | | |
|---|---|---|
| រឿងព្រះថោងនាងនាគទី ១ ដល់-៦ . . . | ១ សៀវភៅថ្លៃ | ១០'០០ |
| ទេវតាភាសិតនឹងពុទ្ធភាសិត . . . . . . . | ,, | ៨'០០ |
| សម្ភារសិក្ខាបទ គោលសិក្សាជំនួយធម្មវិន័យ . | ,, | ១២'០០ |
| វេយ្យាករណបាឋទី ១ . . . . . . . . . . | ,, | ១៨'០០ |
| ,, ,, ទី ២ . . . . . . . . . . | ,, | ១៧'០០ |
| វេយ្យាករណ៍ខ្មែរ . . . . . . . . . . | ,, | ១៣'០០ |
| លេខទៀរ៍ . . . . . . . . . . . . . | ,, | ១៥'០០ |
| បត្តិទានាទិគាថា គឺ ឥមិនាប្រែ . . . . . . | ,, | ៦'០០ |
| ធម្មបញ្ហា . . . . . . . . . . . . . | ,, | ៦'០០ |
| ប្រវត្តិព្រះអរហន្តកធាតុ . . . . . . . . | ,, | ៦'០០ |
| សមាធិនិទ្ទេសសង្ខេប . . . . . . . . . | ,, | ៣០'០០ |
| ប្រស្នាគិហិបដិបត្តិ. . . . . . . . . . | ,, | ១៨'០០ |
| វិធីប្រែបាលី . . . . . . . . . . . | ,, | ២៥'០០ |
| ប្រស្នាអភិធម្ម . . . . . . . . . . | ,, | ២៥'០០ |
| ប្រស្នាត្រៃគុណ . . . . . . . . . . | ,, | ២៥'០០ |
| សាមណេរវិន័យបញ្ហា . . . . . . . . | ,, | ១៨'០០ |

សៀវភៅកំពុងបោះពុម្ព ឬ ប្រុងនឹងបោះពុម្ពតទៅ

រឿងព្រះបាទអជាតសត្រូវ — រឿងមេទ័ពក្រិស

រឿងនិទានទេវទត្ត — រឿងព្រះសុវណ្ណវង្ស

ការផ្សាយរបស់

លេខ ៨៨ វិថីអែមេក្រង ភ្នំពេញ

ជិតរោងកុន ព្រហ្មបាយ័ន ពិចាន់ះគិតញ្ញូប

---

# សេចក្តីជូនដំណឹង

បណ្ណាគារខ្ញុំបាទ មានទទួលបង់គ្រប់សៀវភៅ មានជាវព្រះពុទ្ធរូប បថតផ្សេងៗ គឺព្រះរូបព្រះករុណា និងសម្តេចសង្ឃនាយកជាដើម និងសៀវភៅធម៌ សៀវភៅរឿង គ្រឿងសរសេរ សង្ឃដិកា ធាយា សំបុត្រកំណើត កាតកូនសិស្សនិងសៀវភៅបារាំង-ខ្មែរផ្សេងៗ ជាច្រើន ៗ

សូមទំមត្ត និងអញ្ជើញលោកអ្នកចូលជាវទិញ ដោយមេត្រី ៗ

បើទិញដុំ យកទៅលក់ទៀត ខ្ញុំគិតរង្វាន់ជូនយ៉ាងគួរសម ៗ

ព.ស. ២៤៩៦ គ.ស. ១៩៥៣

ថ្លៃ ១២៛០០

) រោងពុម្ព ភាព-ភាំ ភ្នំពេញ (